# មេរៀនទី ៤ ព្រះវិញ្ញាណដ៏វិសុទ្ធ៖ អ្នកគ្រប់គ្រងដែលប្រកបដោយប្រាជ្ញាញាណ

តើអ្នកធ្លាប់ឆ្ងល់ទេថា ហេតុអ្វីបានជាព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកអ្នកដើរតាមទ្រង់ថា "បើខ្ញុំទៅ ទើបមានប្រយោជន៍ដល់អ្នករាល់គ្នា" (គម្ពីរយ៉ូហាន ១៦:៧)? មូលហេតុគឺដោយសារតែទ្រង់ត្រូវបានស្ថិតនៅក្នុងដែនកំណត់នៃភាពជាមនុស្ស ហើយអាចគង់នៅបានតែមួយកន្លែងក្នុងពេលតែមួយប៉ុណ្ណោះ។ ទោះជាយ៉ាងណា ទ្រង់បានជ្រាបថា នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកជំនួសទ្រង់ នោះនឹងគ្មានដែនកំណត់ទៅលើពេលវេលាដែលទ្រង់អាចគង់នៅបាន ឬ ទៅលើកិច្ចការដែលទ្រង់អាចធ្វើបាននោះទេ។

ដូច្នេះ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះជាម្ចាស់មិនត្រឹមតែដាក់ការងារមួយឲ្យយើងនោះទេ ប៉ុន្តែទ្រង់ក៏គង់នៅជាមួយយើង និង អនុញ្ញាតឲ្យយើងអាចសម្រេចការងារនោះបានផងដែរ។ លើសពីនេះទៅទៀត ទ្រង់បានសង់ដំណាក់ទ្រង់នៅក្នុងយើងរាល់គ្នា និង ប្រទានការនាំផ្លូវដោយផ្ទាល់ សម្ព័ន្ធភាព ការកំសាន្តចិត្ត និងការផ្តល់អំណាចសម្រាប់តម្រូវការខាងឯវិញ្ញាណរបស់យើងផងដែរ។

នៅក្នុងមេរៀនមុនៗ យើងបានឃើញថាការខ្វល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ចំពោះការប្រោសលោះមនុស្ស ។ នៅក្នុងមេរៀនរបស់យើងមុននេះ យើងបានឃើញថា ព្រះគ្រិស្តស្រឡាញ់មនុស្សគ្រប់រូបខ្លាំងណាស់ បានជាទ្រង់បន្ទាបខ្លួនយ៉ាងទាប មកក្លាយជាមនុស្សម្នាក់។ ឥឡូវនេះនៅពេលដែលយើងបង្វែរការយកចិត្តទុកដាក់របស់យើងទៅលើព្រះវិញ្ញាណដ៏វិសុទ្ធវិញ យើងសង្កេតឃើញ សេចក្តីស្រឡាញ់ដូចគ្នានេះ សម្រាប់មនុស្សជាតិ និង ឃើញពីគុណសម្បត្តិ និង បុគ្គលិកលក្ខណៈដ៏អស្ចារ្យដូចគ្នាដែរ។

នៅពេលអ្នកសិក្សាមេរៀននេះ ខ្ញុំសូមអធិស្ឋានសូមឲ្យមានឥទ្ធិពលយ៉ាងពេញលេញនៃអង្គព្រះវិញ្ញាណដ៏វិសុទ្ធ និង កិច្ចការរបស់ទ្រង់បានបង្ហូរមកលើអ្នកជាមួយនឹងអត្ថន័យដ៏អស្ចារ្យជាងពេលមុនៗទៅទៀត។ នៅពេលដែលការនេះកើតឡើង ទំនាក់ទំនងផ្ទាល់របស់អ្នកជាមួយទ្រង់ នឹងបានអភិវឌ្ឍន៍ និង បានឆ្លុះបញ្ចាំងនៅក្នុងព័ន្ធកិច្ចរបស់អ្នកទៅចំពោះអ្នកដទៃ (គម្ពីរ២កូរិនថូស ៣:១៨)។

## *គម្រោងមេរៀន*

ក. ភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

ខ. បុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

គ. ព័ន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

## *វត្ថុបំណងមេរៀន*

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. ស្គាល់ពីលក្ខណសម្បត្តិនៃភាពជាព្រះ ដែលត្រូវបាននិយាយថាជាលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

២. ស្គាល់ពីផ្នែកសំខាន់នៃបុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

៣. ផលឧទាហរណ៍អំពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធធ្វើចំពោះពិភពអ្នកមិនជឿ ធ្វើចំពោះបុគ្គលអ្នកជឿម្នាក់ និង ក្រុមជំនុំទាំងមូល។

៤. បកស្រាយរបៀបប្រាំមួយយ៉ាងដែលព្រះវិញ្ញាណដ៏វិសុទ្ធជួយអ្នកជឿ។

៥. ស្គាល់ពីពាក្យផ្សេងៗទាក់ទងនឹងការជ្រមុជនឹងព្រះវិញ្ញាណ។

៦. ប្រាប់ពីរបៀបដែលអ្នកអាចយក ផ្នត់គំនិតដែលនិមិត្តសញ្ញានីមួយនៃវិញ្ញាណតំណាងឲ្យ ទៅប្រើប្រាស់នៅក្នុងជីវិតរបស់យើង ដើម្បីឲ្យអ្នកអាចបម្រើព្រះអម្ចាស់បានប្រសើរជាងមុន។

៧. រៀបរាប់ពីការផ្តល់អំណាចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ សម្រាប់ការបម្រើ និង ការឆ្លើយតបរបស់អ្នកជឿទៅនឹងការផ្តល់អំណាចនេះ។

## *សកម្មភាពនៅក្នុងការសិក្សា*

១. ដើរតាមនិតិវិធីមេរៀន ដែលបង្ហាញហើយនៅក្នុងមេរៀនទី១។ វាគឺជារឿងសំខាន់ណាស់ដែលអ្នកបើកព្រះគម្ពីររបស់អ្នក ហើយអានខគម្ពីរទាំងអស់ ដែលមេរៀនបានផ្តល់ជូន ដ្បិតខគម្ពីរទាំងនោះគឺមានសារៈសំខាន់ ក្នុងការស្វែងយល់អំពីមេរៀន។

២. ធ្វើការប្រឡងផ្ទាល់ខ្លួន នៅចុងបញ្ចប់នៃមេរៀន ហើយផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក។

៣. បន្ទាប់ពីអ្នកបានធ្វើការប្រឡងផ្ទាល់ខ្លួនរួចហើយ ចូររំឭកមេរៀនទី១ ដល់ ទី៤ (ជំពូកទីមួយ)។ បន្ទាប់មកចូរធ្វើ *ការប្រឡងជំពូកទីមួយ* ។

# ពាក្យសំខាន់

| | | |
|---|---|---|
| ស្នាក្តី | ស្មើភាពគ្នា | សក្តានុពល |
| លក្ខណៈរបស់ | ការបំភ្លឺ | ដាក់បញ្ញត្តិ |
| អំពើកាមគុណ | ការជ្រមុជ | ការបង្កើតឡើងវិញ |
| គ្រឿងបណ្តុំ | អ្នកបកប្រែ | ឆ្អែត ឆ្អើមជោក |
| ចូលរួម | ការលើកទឹកចិត្ត | វេទឃិតភាព |
| ការអនុញ្ញាត | ដើមកំណើត | មិនស៊ីជម្រៅ |
| ការបំភ្លឺឲ្យច្បាស់ | ពហុភាព | |

# ក. ភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

នៅក្នុងការពិចារណារបស់យើងអំពីនិស្ស័យរបស់ព្រះនៅក្នុងមេរៀនទី១ យើងបានពិភាក្សាអំពីសមាសភាពរបស់ទ្រង់ និង កត់ចំណាំចំណុចខាងក្រោមនេះ៖

១. ព្រះជាម្ចាស់គឺជាវិញ្ញាណ
២. ទ្រង់គឺជាព្រះជាម្ចាស់តែមួយគត់។
៣. ទ្រង់មានបុគ្គលិកលក្ខណៈ។
៤. ទ្រង់គឺជាព្រះបីអង្គរួមមកតែមួយ។
៥. ទ្រង់គឺអស់កល្បជានិច្ច។
៦. ទ្រង់មិនផ្លាស់ប្រែ។

យើងក៏បានឃើញថា គុណសម្បត្តិទាំងនេះរបស់ព្រះជាម្ចាស់ និយាយចំពោះព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធស្មើៗគ្នា។ អង្គទាំងបី មានសិរីរុងរឿងស្មើៗគ្នា ហើយព្រះតេជះដែលអង្គព្រះទាំងបីមាន គឺមានភាពអស់កល្បជានិច្ចរួមគ្នា។ ដោយសារតែអង្គព្រះនៅក្នុងព្រះត្រៃឯកភាពពេញលេញមានលក្ខណៈដូចគ្នា យើងមិនបានពិចារណាអំពីទ្រង់ម្តងទៀតនៅក្នុងការពិចារណាអំពីព្រះគ្រិស្តនោះទេ យើងក៏មិនចាំបាច់ត្រូវពិនិត្យពិច័យពីទ្រង់ម្តងទៀតនៅក្នុងការពិនិត្យពិច័យអំពីព្រះវិញ្ញាណដ៏វិសុទ្ធនោះដែរ។ ទោះជាយ៉ាងណា យើងចង់បញ្ជាក់ឡើងវិញម្តងទៀតយ៉ាងខ្លីៗអំពីការពិតដែលថាព្រះវិញ្ញាណដ៏វិសុទ្ធគឺពិតជាព្រះជាម្ចាស់ និង ដែលថាទ្រង់មានលក្ខណសម្បត្តិនៃបុគ្គលិកលក្ខណៈដោយឡែក។ ដំបូងយើងនឹងពិភាក្សាអំពីភាពជាព្រះរបស់ទ្រង់ជាមុនសិន។

ភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គឺបង្កើតឡើងដោយលក្ខណសម្បត្តិរបស់ទ្រង់ ទំនាក់ទំនងរបស់ទ្រង់ជាមួយអង្គព្រះដទៃទៀតនៅក្នុងព្រះត្រៃឯក ព្រះនាមជាព្រះជាម្ចាស់ដែលបានថ្វាយសម្រាប់ទ្រង់ និង កិច្ចការដែលទ្រង់បានសំដែង។

## លក្ខណសម្បត្តិនៃនិស្ស័យជាព្រះរបស់ទ្រង់

**វត្ថុបំណងទី១.** *ស្គាល់ពីលក្ខណសម្បត្តិនៃភាពជាព្រះ ដែលត្រូវបាននិយាយថាជាលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។*

ព្រះវិញ្ញាណដ៏វិសុទ្ធមានលក្ខណសម្បត្តិនៃនិស្ស័យជាព្រះជាម្ចាស់។ ឧទាហរណ៍ ទ្រង់គឺអស់កល្បជានិច្ច។ ពាក្យថា*អស់កល្បជានិច្ច*មានន័យថា "មានរយៈពេលគ្មានទីបញ្ចប់៖ ដែលគ្មានទីចាប់ផ្តើម ឬ ទីបញ្ចប់ ឬ ដែនកំណត់"។ ដូច្នេះ នេះគឺជាលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់។ អ្នកសរសេរសំបុត្រទៅកាន់សាសន៍ហេប្រើដែលទទួលការជំរុញពីព្រះវិញ្ញាណ បានប្រាប់ថា ទ្រង់គឺជា*ព្រះវិញ្ញាណដែលគង់នៅអស់កល្បជានិច្ច* (គម្ពីរហេប្រើ ៩:១៤) ។ ពាក្យថា *អស់កល្បជានិច្ច*ដែលមានប្រើនៅត្រង់នេះ គឺជាពាក្យដូចគ្នាដែលបានប្រើនៅកន្លែងផ្សេងទៀតដើម្បីរៀបរាប់អំពីភាពអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ព្រះវរបិតា និងរបស់ព្រះយេស៊ូគ្រិស្ត ជាបុត្រារបស់ព្រះជាម្ចាស់ដែរ។

ព្រះវិញ្ញាណដ៏វិសុទ្ធក៏មានលក្ខណសម្បត្តិដូចខាងក្រោមនេះដែរះ

១. ទ្រង់មានព្រះវត្តមាននៅគ្រប់ទីកន្លែង (សព្វជ្ញភាព) ។ អ្នកនិពន្ធព្រះបាទដាវីឌបានសំដែងឡើងថាៈ " តើទូលបង្គំអាចទៅណាឆ្ងាយពីព្រះអង្គបាន?តើទូលបង្គំគេចចេញអោយឆ្ងាយពីព្រះភក្ត្ររបស់ព្រះអង្គដូចម្ដេចបាន?" (គម្ពីរទំនុកតម្កើង ១៣៩:៧-១០) ។

២. ទ្រង់ជ្រាបគ្រប់ការទាំងអស់ (សព្វញ្ញូតភាព) ។ នៅក្នុងការរៀបរាប់ពីលក្ខណសម្បត្តិជាព្រះនេះទៅកាន់អ្នកជឿក្រុងកូរិនថូស លោកប៉ូលបានឃើញថា "គ្មានអ្នកណាស្គាល់គំនិតរបស់ព្រះក្រៅពីព្រះវិញ្ញាណរបស់ព្រះនោះឡើយ" (គម្ពីរ(គកស១៦),១កូរិនថូស ២:១១)។ លើសពីនេះទៅទៀត ទ្រង់ដែលយល់ពីព្រះតម្រិះរបស់ព្រះជាម្ចាស់ ក៏យល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ ហើយទ្រង់ផ្ដល់អំណាចឲ្យយើងអាចអធិស្ឋាន ដោយយោងទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ (គម្ពីររ៉ូម៨:២៦-២៧)។

៣. ព្រះវិញ្ញាណដ៏វិសុទ្ធមានអំណាចលើគ្រប់ទាំងអស់ (សព្វានុភាព)។ នោះគឺ ទ្រង់មានអំណាច និងឫទ្ធានុភាព សម្រេចបាននូវអ្វីៗដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ ដោយគ្មានដែនកំណត់សោះឡើយ (គម្ពីរលូកា ១:៣៥ គម្ពីរកិច្ចការ១:៨)។

## លំហាត់អនុវត្តន៍

១ កំណត់លក្ខណសម្បត្តិនីមួយៗ នៃភាពជាព្រះដែលថ្វាយទៅព្រះវិញ្ញាណដ៏វិសុទ្ធ ដោយផ្គូផ្គងលក្ខណសម្បត្តិ (ខាងស្ដាំ) ទៅជាមួយនឹងនិយមន័យនៃលក្ខណសម្បត្តិនីមួយៗ (ខាងឆ្វេង)។

| | |
|---|---|
| .........ក) គ្មានដែនកំណត់ ឬ ព្រំដែន ចំពោះពេលវេលានោះទេ។ | ១) សព្វានុភាព |
| | ២) សព្វញ្ញូតភាព,សព្វញ្ញូតញ្ញាណ |
| .........ខ) សមត្ថភាពនៅពេញសកលលោក ដែលទ្រង់មានព្រះវត្តមាននៅគ្រប់ទីកន្លែង។ | ៣) សព្វជ្ញភាព,សព្វត្ថិភាព |
| | ៤) និរន្តរភាព, អនន្តភាព |
| .........គ) សមត្ថភាពដែលអនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធអាចធ្វើអ្វីៗគ្រប់យ៉ាងតាមបំណងព្រះហឫទ័យព្រះជាម្ចាស់ ដោយគ្មានការរារាំងពីអ្វីឡើយ។ | |
| .........ឃ) ព្រះតម្រិះដែលឥតដែនកំណត់ | |

## ថានន្តរនៃនិស្ស័យជាព្រះរបស់ទ្រង់

វាពិតជាគួរឲ្យចាប់អារម្មណ៍ ដែលយើងចាំថានៅពេលដែលលោកសាវ័កពេត្រុសនិយាយទៅកាន់អាណាណាសដែលមានចិត្តគេងប្រវ័ញ្ច លោកបានមានប្រសាសន៍ថានៅពេលដែលអាណាណាសកុហកព្រះវិញ្ញាណដ៏វិសុទ្ធ លោកកុហកនឹងព្រះជាម្ចាស់ (គម្ពីរកិច្ចការ ៥:៤)។

ដូច្នេះ លោកសាវ័កពេត្រុសថ្វាយភាពជាព្រះទៅដល់ព្រះវិញ្ញាណដ៏វិសុទ្ធ។ លោកសាវ័កប៉ុលក៏បានអះអាងពីការពិតមួយនេះ ដោយមានប្រសាសន៍ថា យើងត្រូវបានផ្លាស់ប្តូរឲ្យបានដូចជាព្រះគ្រិស្ត ដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាព្រះអម្ចាស់ (គម្ពីរ២កូរិនថូស ៣:១៧-១៨) ។ នៅក្នុងជំនាន់របស់លោកសាវ័កប៉ុល មានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលអាចត្រូវបានប្រសព្វនាមជាព្រះអម្ចាស់។ តាមការពិត សូម្បីតែអធិរាជរ៉ូម៉ាំង និង អេស៊ីព្ទ នៅក្នុងជំនាន់នោះ ក៏មិនអនុញ្ញាតឲ្យប្រជារាស្ត្ររបស់ពួកគេប្រើប្រាស់ពាក្យ*ព្រះអម្ចាស់* នៅពេលដែលហៅពួកគេឡើយ លុះត្រាតែពួកគេទទួលបានការតែងតាំងជាអាទិទេពជាផ្លូវការដោយខ្លួនឯង។ ការប្រើប្រាស់នេះ បញ្ជាក់ពីការពិតថា នៅពេលដែលលោកសាវ័កប៉ុលមានប្រសាសន៍អំពីព្រះវិញ្ញាណដ៏វិសុទ្ធ ថាជាព្រះអម្ចាស់ លោកបានស្គាល់ពីភាពជាព្រះរបស់ទ្រង់ទៅហើយ។

## *លំហាត់អនុវត្តន៍*

២ តើបទគម្ពីរណាមួយនៅខាងក្រោមនេះ អាចយកមកប្រើជាភស្តុតាងបង្ហាញពីភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធបាន។

ក) លោកសាវ័កប៉ូលមានប្រសាសន៍សំដៅទៅកាន់ព្រះវិញ្ញាណដ៏វិសុទ្ធ ថាជា*ព្រះអម្ចាស់* ។

ខ) ព្រះយេស៊ូមានព្រះបន្ទូលសំដៅទៅព្រះវិញ្ញាណដ៏វិសុទ្ធថាជា *ទីប្រឹក្សា*។

គ) លោកអេសាយបានមានប្រសាសន៍សំដៅទៅលើ*ព្រះវិញ្ញាណរបស់ព្រះអម្ចាស់* (គម្ពីរអេសាយ ១១:២)។

ឃ) លោកពេត្រុសប្រកាសថា ការកុហកព្រះវិញ្ញាណដ៏វិសុទ្ធគឺការកុហកព្រះជាម្ចាស់។

## *ទំនាក់ទំនងរបស់ទ្រង់ទៅនឹងនិស្ស័យជាព្រះជាម្ចាស់*

ខគម្ពីរជាច្រើនបង្ហាញពីភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ តាមរយៈទំនាក់ទំនងរបស់ទ្រង់។ នៅក្នុងឧទាហរណ៍ពីរដំបូង ដែលមាននៅខាងក្រោមនេះ ភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គឺទទួលបានមកតាមរយៈទំនាក់ទំនងរបស់ទ្រង់ជាមួយនឹងអង្គព្រះពីរទៀតនៅក្នុងព្រះត្រៃឯក។ យើងបានឃើញនៅត្រង់ចំណុចនេះ អំពីគុណសម្បត្តិដ៏សំខាន់មួយរបស់បុគ្គល ក៏ដូចជាភាពជាព្រះសំខាន់ៗផងដែរ។

១. គម្ពីរម៉ាថាយ ២៨:១៩ ៖ *រូបមន្តសំរាប់ការជ្រមុជ៖* "...ហើយធ្វើពិធីជ្រមុជទឹកអោយគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ"។

២. គម្ពីរ២កូរិនថូស ១៣:១៣ ៖ *ប្រសិទ្ធិពររបស់ពួកសាវ័ក៖* "សូមអោយបងប្អូនបានប្រកបដោយព្រះគុណរបស់ព្រះអម្ចាស់យេស៊ូគ្រិស្ត សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងការរួមរស់ក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ" ។

៣. គម្ពីរ១កូរិនថូស ១២។ នៅក្នុងជំពូកមួយនេះ យើងឃើញថាក្រុមជំនុំគឺជាព្រះកាយរបស់ព្រះជាម្ចាស់ (ខ២៧)។ នៅលើក្រុមជំនុំនេះ ព្រះជាម្ចាស់បានចាត់តាំង ឲ្យមានព័ន្ធកិច្ចដើម្បីជួយដល់ការអភិវឌ្ឍ ក្រុមជំនុំនោះ (ខ ២៨)។ ហើយដោយអំណាចគ្រងរាជ្យ(ឫទ្ធានុភាពខ្ពង់ខ្ពស់បំផុត)របស់ព្រះវិញ្ញាណ ដ៏វិសុទ្ធដែលបានចែកចាយអំណោយទាននេះសម្រាប់រូបកាយមួយនេះ (ខ១១)។ ទំនាក់ទំនងទៅ វិញទៅមកដែលយើងឃើញនៅចំណុចនេះ អាចបកស្រាយបានដោយផ្អែកលើមូលដ្ឋានដែលថា មានភាពស្មើគ្នារវាងអង្គព្រះត្រៃឯកតែប៉ុណ្ណោះ។ មានតែការផ្អែកលើមូលដ្ឋាននេះប៉ុណ្ណោះ ដែលអាច ឲ្យព្រះវិញ្ញាណដ៏វិសុទ្ធប្រើប្រាស់សិទ្ធិនៃភាពជាព្រះ និង ចែករំលែកអំណោយទានប្រកបដោយ អធិបតេយ្យភាព តាមបំណងព្រះហឫទ័យរបស់ទ្រង់ (គម្ពីរ១កូរិនថូស ១២:៤-៦,១១)។

៤. គម្ពីរកិច្ចការ ២៨:២៥-២៨។ លោកប៉ូលបានផ្តល់នូវចំណេះដឹងដ៏មានប្រយោជន៍ អំពីបញ្ហានេះ នៅពេលលោកបានមានប្រសាសន៍ថា ព្រះវិញ្ញាណដ៏វិសុទ្ធបានមានព្រះបន្ទូលដែលមានកត់ត្រានៅ ក្នុងគម្ពីរអេសាយ ៦:៩-១០ ដែលយោងតាមលោកអេសាយ គឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ចូរ ប្រៀបធៀបខគម្ពីរទាំងពីរនេះ។ ការប្រៀបធៀបនេះ បង្ហាញថាដោយសារតែព្រះវិញ្ញាណដ៏វិសុទ្ធគឺជា អ្នកតំណាង ឬ ជាភ្នាក់ងាររបស់ព្រះជាម្ចាស់ព្រះវរបិតា ដូច្នេះទ្រង់ធ្វើកិច្ចការជួសឲ្យព្រះវរបិតានៅលើ ផែនដីនេះ។ ការនេះបានបង្ហាញកាន់តែច្បាស់នៅក្នុងឧទាហរណ៍ទាំងនេះ៖ ទ្រង់នាំមនុស្សមករក ព្រះគ្រិស្ត (គម្ពីរយ៉ូហាន ៦:៤៤) ទ្រង់បង្ហាញសេចក្តីពិត (គម្ពីរយ៉ូហាន ១៤:២៦; ១៦:១៣) ហើយ ទ្រង់នាំផ្លូវ (គម្ពីររ៉ូម៨:១៤) ។

៥. គម្ពីរលោកុប្បត្តិជំពូក១។ ការរួមគ្នានៃឫទ្ធានុភាពរបស់ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏ វិសុទ្ធ គឺឃើញមាននៅក្នុងគម្ពីរលោកុប្បត្តិ ១:២៦ ដែលក្នុងនេះព្រះជាម្ចាស់មានព្រះបន្ទូលថា " យើងបង្កើតមនុស្សជាតំណាងរបស់យើង មានលក្ខណៈដូចយើង" ។ ការប្រើប្រាស់សព្វនាម ពហុវចន បង្ហាញពីពហុភាពនៃអង្គព្រះត្រៃឯកភាពពេញលេញ ដូចដែលយើងបានឃើញនៅក្នុងមេ រៀនទី១ ។ អត្ថន័យបង្កប់នៅត្រង់នេះ គឺថាអង្គទាំងបីនៃព្រះជាម្ចាស់គឺសុទ្ធតែមានសកម្មភាពក្នុង ការបង្កើត។

ខគម្ពីរយោងទាំងអស់នេះ ដែលនិយាយអំពីទំនាក់ទំនងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធជាមួយ អង្គ ព្រះពីរទៀតនៅក្នុងព្រះត្រៃឯក បង្ហាញតាមបែបបទគម្ពីរថា ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាព្រះជាម្ចាស់ស្មើគ្នា ជាមួយព្រះវរបិតា និង ព្រះរាជបុត្រាដែរ។

## *លំហាត់អនុវត្តន៍*

៣ ផ្គូផ្គងខគម្ពីរនីមួយៗ (ខាងឆ្វេង) ជាមួយនឹងភស្តុតាងដែលខគម្ពីរនោះផ្តល់ឲ្យ អំពីភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ (ខាងស្តាំ)។

| | | | |
|---|---|---|---|
| .........ក) | គម្ពីរកិច្ចការ ២៨:២៥-២ និងគម្ពីរអេសាយ ៦:៩-១០ | ១) | ពហុភាពនៃអង្គព្រះនៅក្នុង ព្រះត្រៃឯកភាពពេញលេញនៅក្នុងការបង្កើតរបស់សព្វសារពើ |
| .........ខ) | គម្ពីរ១កូរិនថូស ១២ | ២) | កិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅលើផែនដី។ |
| .........គ) | គម្ពីរ២កូរិនថូស ១៣:១៤ | | |
| .........ឃ) | គម្ពីរលោកុប្បត្តិ ១ | ៣) | អធិបតេយ្យរបស់ព្រះជាម្ចាស់ |
| .........ង) | គម្ពីរម៉ាថាយ ២៨:១៩ | ៤) | ភាពស្មើគ្នានៃអង្គព្រះនៅក្នុងព្រះត្រៃឯកភាពពេញលេញ |

# ខ. បុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

**វត្ថុបំណងទី២.** *ស្គាល់ពីផ្នែកសំខាន់នៃបុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។*

## ផ្នែកសំខាន់ៗនៃបុគ្គលិកលក្ខណៈ

យើងបានឃើញរួចមកហើយនៅក្នុងមេរៀនទី១ ថា ផ្នែកសំខាន់ៗនៃបុគ្គលិកលក្ខណៈមានបីយ៉ាង៖ ១) *សតិបញ្ញា* (សមត្ថភាពក្នុងការគិត) ២) *វេទយិតភាព* (សមត្ថភាពក្នុងការមានអារម្មណ៍) និង ៣) *បំណងហឫទ័យ* ( សមត្ថភាពធ្វើការសម្រេចចិត្ត) ។ ចូរយើងទៅសិក្សាអំពីខគម្ពីរដែលនិយាយអំពីព្រះវិញ្ញាណដ៏វិសុទ្ធ ហើយមើលពីរបៀបដែលលក្ខណសម្បត្តិទាំងនេះ ត្រូវបានប្រើប្រាស់ចំពោះទ្រង់។

ព្រះគម្ពីរបានថ្លែងយ៉ាងច្បាស់ៗមកយើង ស្តីពីបុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅក្នុងប្រសាសន៍យ៉ាងម៉ឺងម៉ាត់របស់លោកសាវ័កប៉ូល លោកបានសន្និដ្ឋានដោយនិយាយសំដៅទៅកាន់ "ព្រះបំណងរបស់ព្រះវិញ្ញាណ" (គម្ពីររ៉ូម ៨:២៧) ដែលបានបង្ហាញពីអានុភាពនៃសតិបញ្ញារបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។ លោកសាវ័កប៉ូលក៏បានថ្វាយ*វេទយិតភាព* ទៅកាន់ដល់ព្រះវិញ្ញាណដ៏វិសុទ្ធផងដែរ (គម្ពីររ៉ូម ១៥:៣០)។ ត្រង់នោះ លោកបាននិយាយសំដៅទៅលើសមត្ថភាពរបស់ព្រះវិញ្ញាណ ក្នុងការទទួលអារម្មណ៍ ក្នុងករណីនេះ គឺការមានអារម្មណ៍*ស្រឡាញ់* និង សមត្ថភាពរបស់ទ្រង់ក្នុង*ការបង្ហាញអារម្មណ៍* ។ ចុងក្រោយ លោកសាវ័កប៉ូលបានមានប្រសាសន៍ទៅកាន់អ្នកជឿក្រុងកូរិនថូស អំពីសកម្មភាពជាព្រះអធិបតីរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដូចដែលទ្រង់បានបង្ហាញពីអានុភាពនៃ*បំណងព្រះហឫទ័យ* និង អំពីការប្រទានព្រះអំណោយទានទៅដល់អ្នកជឿ តាមការទ្រង់បានកំណត់ ឬ សព្វព្រះហឫទ័យ (គម្ពីរ១កូរិនថូស ១២:១១) ។ ខគម្ពីរទាំងនេះ បង្ហាញថាព្រះវិញ្ញាណដ៏វិសុទ្ធមានលក្ខណសម្បត្តិសំខាន់ៗខាងឯបុគ្គលិកលក្ខណៈ។

## លំហាត់អនុវត្តន៍

៤ នៅក្នុងលំហាត់ខាងក្រោមនេះ ចូរអ្នកផ្គូផ្គងផ្នែកសំខាន់ៗខាងឯបុគ្គលិកលក្ខណៈ (ខាងស្តាំ) ជាមួយនិយមន័យ ឬការរៀបរាប់របស់បុគ្គលិកលក្ខណៈនោះ (ខាងឆ្វេង)។

| | |
|---|---|
| .........ក) អានុភាពដែលអនុញ្ញាតឲ្យមនុស្សម្នាក់ធ្វើការសម្រេចចិត្ត។ | ១) សតិបញ្ញា |
| .........ខ) សមត្ថភាពដើម្បីរិះគិត រកហេតុផល និង ជ្រាបដឹង | ២) វេទយិតភាព |
| .........គ) សមត្ថភាពដើម្បីទទួលបានអារម្មណ៍ ដើម្បីបង្ហាញពីអារម្មណ៍។ | ៣) បំណងហឫទ័យ |

## ចំណុចសំខាន់ផ្សេងៗទៀតនៃបុគ្គលិកលក្ខណៈ

បន្ថែមពីលើផ្នែកចាំបាច់នៃបុគ្គលិកលក្ខណៈទាំងអស់ មានចំណុចសំខាន់ៗខ្លះទៀតដែលរួមបញ្ចូលនៅក្នុងការយល់ដឹងរបស់យើងអំពីបុគ្គលិកលក្ខណៈ។ ចំណុចទាំងនោះមានដូចជា ១) ទំនាក់ទំនងជាបុគ្គល ២) ទង្វើ ឬ សកម្មភាពជាបុគ្គល ៣) នាមជាបុគ្គល ៤) សព្វនាមជាបុគ្គល និង ៥) ការប្រព្រឹត្តជាបុគ្គល។ លក្ខណសម្បត្តិទាំងអស់នេះក៏អាចយកទៅប្រើជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធបានផងដែរ ដូចដែលយើងនឹងបានឃើញនៅខាងក្រោមនេះ ។

១. *ទំនាក់ទំនងជាបុគ្គល*

យើងបានកត់សំគាល់ឃើញថា រូបមន្តសម្រាប់ការជ្រមុជ និង ការប្រសិទ្ធិពររបស់ពួកសាវ័ក ព្រះវិញ្ញាណដ៏វិសុទ្ធត្រូវបានលើកយកមកថ្លែងរួមជាមួយព្រះវរបិតា និង ព្រះរាជបុត្រា។ ការទំនាក់ទំនងជាមួយបុគ្គលផ្សេងនេះ បញ្ជាក់ឲ្យឃើញពីបុគ្គលិកលក្ខណៈ។ តើវាមិនមែនជារឿងដ៏ល្ងង់ខ្លៅមួយទេឬអី ដែលបង្គាប់ឲ្យនរណាម្នាក់ជ្រមុជទឹកនៅក្នុងព្រះនាមព្រះវរបិតា និង ព្រះរាជបុត្រា និង " កម្លាំង" "ដង្ហើម" ឬ "ខ្យល់" វិញនេះ ? ( គម្ពីរម៉ាថាយ ២៨:១៩)។ នោះពិតជារឿងដ៏ល្ងង់ខ្លៅណាស់ ដ្បិតមានតែបុគ្គលិកលក្ខណៈប៉ុណ្ណោះដែលអាច មានទំនាក់ទំនងជាមួយនឹងបុគ្គលិកលក្ខណៈដទៃផ្សេងទៀត។

នេះប្រាកដជាមូលដ្ឋានដែលពួកសាវ័ក និង ព្រឹទ្ធាចារ្យមានកិច្ចប្រជុំប្រឹក្សាសំខាន់នៅក្រុងយេរូសាឡឹម បានសរសេរពាក្យទាំងនេះថា៖ " ព្រះវិញ្ញាណដ៏វិសុទ្ធ* និងយើងខ្ញុំយល់ឃើញថា មិនគួរយកវិន័យ*ណាផ្សេងទៀតដែលមិនចាំបាច់ មកបង្ខំបងប្អូនអោយប្រតិបត្តិតាមឡើយ" (គម្ពីរកិច្ចការ ១៥:២៨) ។ បុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គឺបានបញ្ជាក់ឲ្យឃើញដោយទំនាក់ទំនងរបស់ទ្រង់ជាមួយនឹងអង្គព្រះពីរផ្សេងទៀតនៅក្នុងព្រះត្រៃឯក។

២. *ទង្វើ ឬ សកម្មភាពជាបុគ្គល*

នៅពេលដែលយើងពិចារណាអំពីសកម្មភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានបង្ហាញនៅក្នុងខគម្ពីរ យើងនឹងឃើញពីរបៀបដែលខគម្ពីរទាំងនោះប្រាប់ពីនិយមន័យពេញលេញ ទៅកាន់បុគ្គលិកលក្ខណៈរបស់ទ្រង់។ ចូរអ្នកអានខគម្ពីរនីមួយៗខាងក្រោមនេះ។

| ខគម្ពីរ | សកម្មភាពនៃលក្ខណៈបុគ្គល |
|---|---|
| គម្ពីរ២ពេត្រុស ១:២១ | ព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញ លើកទឹកចិត្ត និង ផ្តល់អំណាច |
| គម្ពីរ១កូរិនថូស ២:១០ | ទ្រង់ស្វែងរក |
| គម្ពីរកិច្ចការ ១៣:២<br>គម្ពីរវិវរណៈ ២:៧ | ទ្រង់មានព្រះបន្ទូល ត្រាស់ហៅមនុស្សឲ្យធ្វើការបម្រើ |
| គម្ពីរយ៉ូហាន ១៥:២៦ | ទ្រង់ធ្វើបន្ទាល់ |
| គម្ពីរកិច្ចការ១៦:៦-៧ | ទ្រង់ដឹកនាំ មនុស្សរបស់ទ្រង់នៅក្នុងការបម្រើ ជាពិសេសតែងតែរារាំង និង ហាមឃាត់ពួកគេមិនឲ្យធ្វើសកម្មភាពខ្លះៗ |
| គម្ពីររ៉ូម ៨:២៦ | ទ្រង់ទូលអង្វរជំនួសយើង |
| គម្ពីរយ៉ូហាន ១៤:២៦ | ទ្រង់បង្រៀន |
| គម្ពីរយ៉ូហាន ១៦:៨-១១ | ទ្រង់កាត់ទោស |
| គម្ពីរយ៉ូហាន ១៦:១៣ | ទ្រង់នាំផ្លូវយើង |
| គម្ពីរយ៉ូហាន ១៦:១៤ | ទ្រង់ថ្វាយសិរីរុងរឿងដល់ព្រះគ្រិស្ត |
| គម្ពីរយ៉ូហាន ៣:៥ | ទ្រង់បង្កើតយើងជាថ្មី |

## លំហាត់អនុវត្តន៍

៥ តើសកម្មភាពខាងលើនេះបានបង្ហាញអ្វី អំពីនិស្ស័យរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ? ចូរសរសេរចម្លើយនៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

៣. *ព្រះនាមជាបុគ្គល*

នៅល្ងាចនៃថ្ងៃដែលទ្រង់ត្រូវគេឆ្កាង ព្រះយេស៊ូបានសំដែងទៅកាន់ពួកសិស្សរបស់ទ្រង់ថា ទ្រង់នឹងចាកចេញពីពួកគេ។ ដោយដឹងថាការចាកចេញរបស់ទ្រង់ ក៏មានន័យថាដកការដឹកនាំរបស់ទ្រង់ ការធានាអះអាង និង ការប្រឹក្សារបស់ទ្រង់ចេញពីពួកគេ ព្រះយេស៊ូបានមានព្រះបន្ទូលថា៖ "ខ្ញុំនឹងទូលអង្វរព្រះបិតា ហើយទ្រង់ប្រទានព្រះដ៏ជួយការពារមួយអង្គទៀត អោយគង់នៅជាមួយអ្នករាល់គ្នាជាដរាបតរៀងទៅ" (គម្ពីរយ៉ូហាន ១៤:១៦)។

ភ្លាមៗនេះព្រះយេស៊ូក៏បានបង្ហាញថា ព្រះមួយអង្គទៀតដែលនឹងជំនួសកន្លែងទ្រង់គឺជាព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីរយ៉ូហាន ១៤:២៦) ។ ព្រះក៏បានបញ្ជាក់ថែមទៀតថា ដូចដែលទ្រង់បានយាងមកដើម្បីប្រកាសអំពីព្រះវរបិតា ព្រះវិញ្ញាណដ៏វិសុទ្ធក៏យាងមកដើម្បីពន្យល់ បង្ហាញ និង បកស្រាយ

និស្ស័យនិង បំណងព្រះហឫទ័យរបស់ព្រះយេស៊ូទៅកាន់មនុស្សជាតិដែរ។ (ចូរប្រៀបធៀបខគម្ពីរទាំងនេះ ៖ គម្ពីរយ៉ូហាន ១៤:១៥-១៨, ២៦; ១៥:២៦ និង ១៦:១៣-១៥)។ យើងឃើញហើយថា ព្រះវិញ្ញាណដ៏វិសុទ្ធ ត្រូវបានគេហៅថា *ព្រះដ៏ជួយការពារ* ហើយទ្រង់យាងមកដើម្បីជំនួសកន្លែងរបស់ព្រះយេស៊ូ និង បំពេញព័ន្ធកិច្ចរបស់ព្រះគ្រិស្ត ជាអ្នកជួយការពារ *មួយអង្គទៀត*។ ទំនួលខុសត្រូវនេះ ទាមទារឲ្យមានការវិនិច្ឆ័យបានល្អ អារម្មណ៍ បុគ្គលិកលក្ខណៈងាយទទួលដឹង ដែលអាចធ្វើការជួសឲ្យព្រះបុត្រារបស់ព្រះជាម្ចាស់បាន។

ព្រះវិញ្ញាណដ៏វិសុទ្ធ ត្រូវបានចាត់បញ្ជូនមកដោយព្រះវរបិតា តាមសំណើររបស់ព្រះបុត្រា (គម្ពីរយ៉ូហាន ១៥:២៦) ដើម្បីតម្កើងសិរីរុងរឿងព្រះបុត្រា និង ព័ន្ធកិច្ចរបស់ទ្រង់ទៅកាន់តម្រូវការខាងឯវិញ្ញាណរបស់អ្នកជឿ។ ទ្រង់ត្រូវបានគេហៅថា *ព្រះវិញ្ញាណដែលសំដែងសេចក្តីពិត* (គម្ពីរយ៉ូហាន ១៤:១៧) ព្រះវិញ្ញាណដែលផ្តល់ជីវិត(គម្ពីររ៉ូម ៨:២) ព្រះវិញ្ញាណនៃព្រះគុណ (គម្ពីរហេប្រឺ១០:២៩) *ព្រះវិញ្ញាណនៃការទទួលជាបុត្រ* (គម្ពីររ៉ូម៨:១៥ គម្ពីរកាឡាទី ៤:៥-៧) *ព្រះវិញ្ញាណនៃព្រះបន្ទូលសន្យា* (គម្ពីរកិច្ចការ ១:៥) *ព្រះវិញ្ញាណនៃភាពវិសុទ្ធ* (គម្ពីររ៉ូម ១:៤) និង *អ្នកទូលអង្វរជួស* ឬ *ព្រះដ៏ជួយការពារ* (គម្ពីរ១យ៉ូហាន ២:១ គម្ពីរយ៉ូហាន ១៤:១៦,២៦)។ ព្រះដែលមានព្រះនាមទាំងអស់ខាងលើនេះ គឺជាព្រះវិញ្ញាណដ៏វិសុទ្ធតែមួយដែលបានថ្វាយសិរីរុងរឿងរបស់ព្រះយេស៊ូ ធ្វើឲ្យទ្រង់បានមានភាពជាក់ស្តែងសម្រាប់យើងរាល់គ្នា ហើយបន្តកិច្ចការរបស់ទ្រង់នៅលើផែនដី។

ព្រះដ៏ជួយការពារអង្គនេះ ក៏ត្រូវបានគេហៅថា *ព្រះវិញ្ញាណដ៏វិសុទ្ធ* (គម្ពីរអេភេសូ ៤: ៣០) ព្រះវិញ្ញាណរបស់ព្រះយេស៊ូ (គម្ពីរកិច្ចការ ១៦:៧) ព្រះវិញ្ញាណរបស់ព្រះគ្រិស្ត (គម្ពីររ៉ូម ៨:៩) ព្រះវិញ្ញាណរបស់ព្រះយេស៊ូគ្រិស្ត (គម្ពីរភីលីព ១:១៩) និង ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ (គម្ពីរ១យ៉ូហាន ៤:២) ។ ទោះបីជាព្រះនាមទាំងនេះខុសគ្នាក៏ដោយ ការហៅនេះគឺសំដៅតែទៅលើព្រះមួយអង្គគត់។ ព្រះនាមផ្សេងគ្នានេះ គឺគ្រាន់តែបង្ហាញអំពីផ្នែកផ្សេងៗគ្នានៃនិស្ស័យ និង ព្រះរាជកិច្ចរបស់ទ្រង់តែប៉ុណ្ណោះ។

៤. *សព្វនាមជាបុគ្គល*

អ្នកប្រហែលជាបានសំគាល់ឃើញពីការយកចិត្តទុកដាក់អំពីព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងគម្ពីរយ៉ូហានជំពូក១៤,១៥និង១៦ រួចមកហើយ។ វាគឺជារឿងចាំបាច់ណាស់ ដែលលោកយ៉ូហានប្រើប្រាស់សព្វនាមបុរិសៈ ដើម្បីទាក់យកចំណាប់អារម្មណ៍ទៅលើភាពជាបុគ្គលរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ឧទាហរណ៍ សព្វនាមជាបុរស *អេខេនូស (ekeinos)* ត្រូវបានយកមកប្រើប្រាស់នៅក្នុងគម្ពីរយ៉ូហាន ១៦:១៣ ដើម្បីនិយាយអំពីព្រះវិញ្ញាណដ៏វិសុទ្ធ ជាប្រយោជន៍ក្នុងការសំគាល់ពីភាពជាបុគ្គលរបស់ទ្រង់។ នេះគឺជាសព្វនាមដូចគ្នាទៅនឹងសព្វនាមដែលបានប្រើប្រាស់ដើម្បីនិយាយអំពីព្រះយេស៊ូ នៅក្នុងគម្ពីរ១យ៉ូហាន ២:៦; ៣:៣,៥,៧ និង១៦។

៥. ការប្រព្រឹត្តជាបុគ្គល។

ចុងបញ្ចប់ ការពិតដែលថាព្រះវិញ្ញាណដ៏វិសុទ្ធ ត្រូវទទួលរងការប្រព្រឹត្តិមកចំពោះទ្រង់ដូចជាបុគ្គលក៏បានបង្ហាញទៅកាន់ភាពជាបុគ្គលរបស់ទ្រង់ផងដែរ។ បទគម្ពីរបានសំដែងថា ទ្រង់អាចត្រូវល្បងលឬល្បួង (គម្ពីរកិច្ចការ ៥:៩) ត្រូវធ្វើឲ្យព្រួយព្រះទ័យ (គម្ពីរអេភេសូ ៤:៣០) ត្រូវបានកុហក (គម្ពីរកិច្ចការ ៥:៣) ត្រូវបានប្រមាថ និង និយាយទាស់ប្រឆាំង (គម្ពីរម៉ាថាយ ១២:៣១-៣២) ត្រូវបានជំទាស់ប្រឆាំង

(គម្ពីរកិច្ចការ ៧:៥១) និង ត្រូវបានត្មះតិះដៀល (គម្ពីរហេប្រឺ១០:២៩) ។ កម្លាំងអបុគ្គល មិនត្រូវបាន ទទួលរងនូវការប្រព្រឹត្តិយ៉ាងដូច្នេះឡើយ ហើយក៏មិនអាចនឹងមានឥរិយាបថឆ្លើយតបដូច្នេះបានដែរ។

## លំហាត់អនុវត្តន៍

៦ តើពាក្យណាខ្លះនៅខាងក្រោមនេះ ដែលអាចយកទៅប្រើដើម្បីរៀបរាប់អំពីព្រះវិញ្ញាណដ៏វិសុទ្ធបាន យ៉ាងត្រឹមត្រូវ ? ចូរគូសរង្វង់ជុំវិញ អក្សរនៅខាងមុខចម្លើយរបស់អ្នក។

| | |
|---|---|
| ក) ព្រះដ៏ជួយការពារ | ជ) ព្រះដែលត្រូវបានល្បួង |
| ខ) អ្នកនាំផ្លូវ | ឈ) បុគ្គលម្នាក់ |
| គ) កម្លាំងអបុគ្គល | ញ) គ្រូ |
| ឃ) ទ្រង់ | ដ) ដែលប្រកបដោយសតិបញ្ញា |
| ង) ភាពជាព្រះ | ឋ) ព្រះដែលគ្រងរាជ្យ |
| ច) អ្នកទូលអង្វរជួស | ឌ) ព្រះដែលទទួលជ្រាបអារម្មណ៍ |
| ឆ) វា | ឍ) ព្រះដែលអាចនឹងត្រូវត្មះតិះដៀល |

ការស្គាល់ពីភាពជាបុគ្គលរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គឺមានសារៈសំខាន់ណាស់។ នៅពេលដែល យើងដឹងថា ទ្រង់គឺជាភាពបុគ្គលមួយទៀតនៅក្នុងព្រះត្រៃឯកភាពពេញលេញ យើងឃើញថាទ្រង់ស័ក្តិស មទទួលបានការថ្វាយបង្គំរបស់យើង ជំនឿរបស់យើង ក្តីស្រឡាញ់ និង ការលើកតម្កើងរបស់យើង។ រឿង ដែលយើងត្រូវធ្វើគឺអនុញ្ញាតឲ្យទ្រង់គង់នៅក្នុងយើង ហើយប្រើប្រាស់យើងសម្រាប់ព្រះកិត្តិនាម និង សិរី រុងរឿងរបស់ទ្រង់។

## គ. ព័ន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

យើងបានឃើញផ្នែកមួយនៃព័ន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ នៅពេលដែលទ្រង់ធ្វើសកម្មភាព ជាមួយព្រះវរបិតា និង ព្រះបុត្រា ក្នុងការបង្កើតរបស់សព្វសារពើហើយ។ ដោយយោងទៅតាមការចូលរួម នេះ អ្នកនិពន្ធគម្ពីរទំនុកតំម្កើងបានថ្លែងថា៖ "ពេលណាព្រះអង្គប្រទានខ្យល់ដង្ហើម សត្វទាំងនោះនឹង កកើតឡើងហើយអ្វីៗទាំងអស់នៅលើផែនដីមានជីវិតឡើងវិញ។" (គម្ពីរទំនុកតម្កើង ១០៤:៣០)។ ខគម្ពីរ យោងដែលយើងនឹងបានឃើញ ក៏មាននិយាយអំពីតួនាទីរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងការការពារ នឹង ថែរក្សា ស្នាព្រះហស្តរបស់ព្រះជាម្ចាស់ផងដែរ។

នៅពេលដែលលោកហោរាអេសាយមានប្រសាសន៍អំពីភាពអស្ចារ្យគ្មានដែនកំណត់នៃឫទ្ធានុភាព របស់ព្រះជាម្ចាស់នៅក្នុងការបង្កើតរបស់សព្វសារពើ និង ឧបការគុណ (ការនាំផ្លូវ ឬការថែរក្សាពីព្រះជា ម្ចាស់) លោកបានចោតសួរថា "តើនរណាស្ទង់ព្រះវិញ្ញាណនៃព្រះអម្ចាស់ តើនរណាធ្វើជាទីប្រឹក្សា ជួយ គំនិតព្រះអង្គ?" (គម្ពីរអេសាយ ៤០:១៣)។ នៅពេលពិចារណាអំពីសំណួរមួយនេះ យើងចាប់ផ្តើមឃើញពី ដែនកំណត់នៃសមត្ថភាពរបស់យើងក្នុងការយល់ពីភាពអាថ៌កំបាំងរបស់ព្រះជាម្ចាស់។ ដូច្នេះ យើងអាច បានត្រឹមតែ ឆ្លើយទៅនឹងសំណួរនេះដោយនិយាយថា យើងមិនអាចយល់ច្បាស់ពីព្រះវិញ្ញាណដ៏វិសុទ្ធ នោះទេ ប៉ុន្តែយើងអាចទទួលបានការប៉ះពាល់ ទទួលបានព្រះពរ និង ការដឹកនាំដោយព្រះវត្តមានរបស់

ទ្រង់ ហើយទទួលបានអំណាចតាមរយៈឫទ្ធានុភាពរបស់ទ្រង់។ យើងអាចឃើញពីឥទ្ធិពលនៃព័ន្ធកិច្ចរបស់ទ្រង់ ដូចដែលយើងអាចឃើញពីឥទ្ធិពលរបស់ខ្យល់ ទោះបីជាយើងមិនយល់ច្បាស់ពីអាថ៌កំបាំងរបស់ខ្យល់នោះផងដែរ។ (គម្ពីរយ៉ូហាន ៣:៨)

ស្របពេលដែលយើងរាល់គ្នាដែលជាសភាវៈមានដែនកំណត់ មិនអាចយល់បានយ៉ាងពេញលេញអំពីវិសាលភាពនៃសកម្មភាពដែលឥតដែនកំណត់របស់ព្រះវិញ្ញាណបាន យើងនៅតែអាចសិក្សាអំពីផ្នែកខ្លះៗនៃសកម្មភាពរបស់ទ្រង់ដែលបានបង្ហាញនៅក្នុងបទគម្ពីរ។ ការបើកបង្ហាញរបស់ បទគម្ពីរទាំងនេះ ផ្តល់ឲ្យយើងនូវរូបភាពស្ទើរតែគ្រប់ជ្រុងជ្រោយនៃអង្គព្រះវិញ្ញាណដ៏វិសុទ្ធ និង វិសាលភាពដ៏ធំធេងនៃព័ន្ធកិច្ចរបស់ទ្រង់។ យើងគួរតែពិចារណាអំពី ព័ន្ធកិច្ចរបស់ទ្រង់ដែលទាក់ទងនឹង ១)ពិភពលោករបស់អ្នកមិនជឿ ២) អ្នកជឿម្នាក់ៗ និង ៣) ក្រុមជំនុំទាំងមូល។

## ទាក់ទងនឹងពិភពលោករបស់អ្នកមិនជឿ

**វត្ថុបំណងទី៣.** *ផលឧទាហរណ៍អំពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធធ្វើចំពោះពិភពអ្នកមិនជឿ ធ្វើចំពោះបុគ្គលអ្នកជឿម្នាក់ និង ក្រុមជំនុំទាំងមូល។*

លើសពីការចូលរួមរបស់ទ្រង់នៅក្នុងការបង្កើតរបស់សព្វសារពើ និង ឧបការគុណរបស់ទ្រង់ ព្រះវិញ្ញាណដ៏វិសុទ្ធក៏បានចូលរួមនៅក្នុងពិភពលោករបស់អ្នកមិនជឿផងដែរ។ យោងទៅតាមគម្ពីរយ៉ូហាន ១៦:៨-១១ ទ្រង់ប្រកាសប្រាប់មនុស្សអំពីអំពើបាប ភាពសុចរិត និង   ការកាត់ទោស។

១. *ប្រកាស(បញ្ជាក់)ប្រាប់ពីអំពើបាប។*

ព្រះយេស៊ូបានមានព្រះបន្ទូលថា នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកដល់ "ព្រះអង្គនឹងបញ្ជាក់អោយមនុស្សលោកដឹងថា គេយល់ខុសអំពីបាប* អំពីសេចក្តីសុចរិត* និងអំពីការកាត់ទោស។ គេយល់ខុសអំពីបាប ព្រោះគេមិនជឿលើខ្ញុំ" (គម្ពីរយ៉ូហាន១៦:៨-៩)។ ព្រះវិញ្ញាណដ៏វិសុទ្ធ បញ្ជាក់ឲ្យមនុស្សដឹងអំពីភាពមានបាបដែលមកពីការមិនទទួលជឿលើព្រះយេស៊ូគ្រិស្ត។

២. *ប្រកាស(បញ្ជាក់)ប្រាប់អំពីភាពសុចរិត។*

"....អំពីសេចក្តីសុចរិតព្រោះខ្ញុំទៅឯព្រះបិតា ហើយអ្នករាល់គ្នានឹងមិនឃើញខ្ញុំទៀត" (គម្ពីរយ៉ូហាន ១៦:១០)។ នោះមានន័យថា ព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញទៅកាន់មនុស្សលោកអំពីភាពសុចរិតរបស់ព្រះអម្ចាស់យេស៊ូគ្រិស្ត និង ភាពទុច្ចរិតរបស់អ្នកដទៃផ្សេងទៀត។ ទ្រង់ក្រើនរំឭកពួកគេថា ដោយសារតែជ័យជំនះរបស់ព្រះយេស៊ូលើអំពើបាប ទើបពេលនេះព្រះជាម្ចាស់ប្រកាសថាមនុស្សបាបបានទៅជាសុចរិត និងអនុញ្ញាតឲ្យពួកគេធ្វើខ្លួនឲ្យបានសុចរិត តាមរយៈជំនឿរបស់ពួកគេលើទ្រង់។

៣. *ប្រកាស(បញ្ជាក់)ប្រាប់អំពីការកាត់ទោស។*

"....អំពីការកាត់ទោស ព្រោះចៅហ្វាយរបស់មនុស្សលោកនេះបានទទួលទោសរួចហើយ។" (គម្ពីរយ៉ូហាន ១៦:១១) ។ ព្រះវិញ្ញាណដ៏វិសុទ្ធប្រកាស(បញ្ជាក់)ប្រាប់អ្នកមិនជឿអំពីការកាត់ទោស តាមរយៈការបង្ហាញទំនាក់ទំនងរវាងការសុគតរបស់ព្រះគ្រិស្ត និង ការមានព្រះជន្មរស់ឡើងវិញ និង ការវិនិច្ឆ័យទោសបាបពិភពលោកនេះ។ តាមរយៈការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ទ្រង់បានក្លាយជាអ្នកមានជ័យជំនះលើខ្មាំងសត្រូវគឺសាតាំង ដែលជាត្រូវបានកាត់ទោសឲ្យស្លាប់ជារៀងរហូត។ ដូច្នេះ ឃើ

ឆ្កាងសំគាល់ពីការបង់ថ្លៃបំណុលមួយ ដែលជាបំណុលទោសបាបរបស់យើង។ ឈើឆ្កាងក៏សំគាល់ពីការប្រទានការរំដោះបាប,សសម្រាប់អស់អ្នកដែលនឹងទទួលឈើឆ្កាង ហើយច្រានចោលអំណាចរបស់អំពើបាប និង សាតាំង។

សេចក្ដីបង្រៀនរបស់ព្រះយេស៊ូ អំពីព័ន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីរយ៉ូហាន ១៤:១៦-១៧, ២៦; ១៥:២៦; ១៦:៥-១៥) បាននាំយើងឲ្យចូលទៅរកការសន្និដ្ឋានដែលថានៅក្នុងពេលគ្មានព្រះវត្តមានព្រះអម្ចាស់យេស៊ូនៅលើផែនដីនេះ ហើយដើម្បីជំនួសឲ្យព្រះវរបិតា ព្រះវិញ្ញាណដ៏សុទ្ធគឺជាព្រះដែលជាសក្ខីភាពទៅដល់អ្នកមិនជឿ។ ព្រះវិញ្ញាណបានបញ្ជាក់ប្រាប់ ពួកគេអំពីអំពើបាប និង នាំពួកគេឲ្យបានចូលទៅឯព្រះគ្រិស្ដ (គម្ពីរយ៉ូហាន ៦:៤៤) ។ បន្ទាប់មកទ្រង់បានបំភ្លឺផ្លូវសម្រាប់អ្នកជឿអំពីទំនួលខុសត្រូវខាងឯវិញ្ញាណរបស់ពួកគេ (គម្ពីរ១យ៉ូហាន ១:៩) ។

## *លំហាត់អនុវត្តន៍*

៧ តើចម្លើយមួយណានៅខាងក្រោមនេះ ជាឧទាហរណ៍ត្រឹមត្រូវអំពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធធ្វើព័ន្ធកិច្ចជាមួយនឹងពិភពលោករបស់អ្នកមិនជឿ? ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយរបស់អ្នក។

ក) ព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញមនុស្សទុច្ចរិតថា មធ្យោបាយតែមួយគត់ដើម្បីឲ្យពួកគេក្លាយទៅជាសុចរិត គឺតាមរយៈជំនឿទៅលើការរំដោះបាបរបស់ព្រះគ្រិស្ដ។

ខ) តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះវត្តមាននៅលើផែនដីនេះ ទ្រង់បានយកឈ្នះលើកចុងក្រោយលើសាតាំង។

គ) យើងបានឃើញថា ព្រះគ្រិស្ដបានបង់លោះទោសនៃអំពើបាបម្ដងរួចហើយ ហើយដោយព្រោះការទាំងនេះ ព្រះវិញ្ញាណដ៏វិសុទ្ធអាចបញ្ចុះបញ្ចូលអ្នកមិនជឿអំពីការវិនិច្ឆ័យទោសរបស់ព្រះជាម្ចាស់។

ឃ) ព្រះវិញ្ញាណដ៏វិសុទ្ធប្រកាសប្រាប់ក្នុងចិត្តអ្នកមិនជឿអំពីអំពើបាប។

# ទាក់ទងជាមួយនឹងអ្នកជឿម្នាក់ៗ

## ជំនួយរបស់ទ្រង់

**វត្ថុបំណងទី៤.** *បកស្រាយរបៀបប្រាំមួយយ៉ាងដែលព្រះវិញ្ញាណដ៏វិសុទ្ធជួយអ្នកជឿ។*

ចូរយើងពិចារណាអំពីព័ន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ទៅចំពោះអ្នកជឿ ទៅតាមប្រភេទពីរយ៉ាង៖ ១) ជំនួយរបស់ទ្រង់ និង ការជ្រមុជរបស់ទ្រង់។ ព្រះយេស៊ូបានប្រាប់ទៅពួកសាវ័ករបស់ទ្រង់ថា ការចាកចេញរបស់ទ្រងពីពួកគេទៅគឺប្រសើរជាង ព្រោះព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមកជួយពួកគេបន្ទាប់ពីទ្រង់ (គម្ពីរយ៉ូហាន ១៦:៧) ។ ខ្ញុំពិតជាស្ញប់ស្ញែងណាស់ដែលបានឃើញពីជំនួយជាច្រើនប្រភេទដែលអ្នកជឿអាចទទួលបានពីទ្រង់។

១. *យើងក្លាយខ្លួនជាអ្នកជឿ តាមរយៈកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ*

ពេលដែលយើងនៅជាអ្នកមិនជឿ យើងបានស្លាប់ខាងឯវិញ្ញាណទៅហើយ ប៉ុន្តែនៅពេលដែលយើងចូលមកឯព្រះជាម្ចាស់ ជាមួយនឹងការលន់តួ និង ជំនឿ យើងបានកើតជាថ្មីខាងឯជំនឿ។ យើងបានក្លាយជាការបង្កើតថ្មីមួយ (គម្ពីរ២កូរិនថូស ៥:១៧)។ យើងក៏បានកើតជាថ្មីម្ដងទៀត ដោយសារព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ហើយយើងបានទទួលនិស្ស័យថ្មីមួយ។ បទពិសោធន៍មួយនេះ ត្រូវបានអ្នកទេវវិទូហៅថា *កំណើតថ្មី*។ (ចូរមើលគម្ពីរយ៉ូហាន ៣:៥-៧ គម្ពីរអេភេសូ ២:៥ និង គម្ពីរទីតុស ៣:៥) ។

២. *យើងទទួលបានឫទ្ធានុភាពពីព្រះវិញ្ញាណ សម្រាប់ធ្វើសក្ខីភាព។*

(គម្ពីរកិច្ចការ១:៨) ។ បញ្ហាកើតឡើងនៅពេលដែលយើងធ្វើការសម្រេចចិត្តដើម្បីចែកចាយដំណឹងល្អជាមួយអ្នកដទៃ។ កាលៈទេសៈ មនុស្ស និង វិញ្ញាណអាក្រក់ព្យាយាមរារាំងយើង។ យើងត្រូវតែមានឫទ្ធានុភាពពិសេសដើម្បីយកឈ្នះលើឧបសគ្គទាំងអស់នេះ។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់គឺជាប្រភពនៃឫទ្ធានុភាពដែលយើងត្រូវការទាញយកមកដាក់ក្នុងខ្លួនដើម្បីឲ្យធ្វើសក្ខីភាពប្រកបដោយប្រសិទ្ធិភាព។

៣. *ព្រះវិញ្ញាណដ៏វិសុទ្ធ ជួយដឹកនាំយើងក្នុងនាមជាគ្រូម្នាក់* (គម្ពីរយ៉ូហាន ១៤:២៦; ១៥:២៦; ១៦:១៣)។

ខ្ញុំប្រហែលជាមិនបានរៀននៅក្នុងថ្នាក់របស់អភិជនអ្វីនោះទេ ប៉ុន្តែនៅពេលខ្ញុំចូលទៅកាន់ព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីរកជំនួយ ទ្រង់នឹងបង្រៀនខ្ញុំ។ ទ្រង់សព្វព្រះហឫទ័យបង្ហាញមកកាន់ខ្ញុំ អំពីសេចក្ដីពិតរបស់ព្រះជាម្ចាស់ ដូចទ្រង់សព្វព្រះហឫទ័យបង្ហាញទៅកាន់អ្នកដទៃទៀតដែរ (គម្ពីរ១កូរិនថូស ២:១២-១៤)។

៤. *យើងក៏បានទទួលជំនួយពីព្រះវិញ្ញាណដ៏វិសុទ្ធ តាមរយៈការទូលអង្វរជំនួសយើងផងដែរ។*

នេះមានន័យថា ទ្រង់ជាតំណាងនៃតម្រូវការរបស់យើងនៅចំពោះព្រះភ័ក្ត្រព្រះវរបិតានៃស្ថានបរមសុខ។ តើអ្នកធ្លាប់មានអារម្មណ៍ដូចខ្ញុំទេ ថានៅក្នុងស្ថានភាពមួយចំនួន អ្នកមិនដឹងអធិស្ឋានយ៉ាងដូចម្ដេចនោះទេ? ពេលខ្លះយើងមានអារម្មណ៍ថា មិនចង់អធិស្ឋានសោះតែម្ដង។ នៅក្នុងគ្រាបែបនេះ យើងអាចពឹងលើសេចក្ដីអធិស្ឋានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធបាន (គម្ពីររ៉ូម ៨:២៦)។

៥. *ព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំយើង ពីមួយថ្ងៃទៅមួយថ្ងៃ ឆ្ពោះទៅរកជីវិតប្រកបដោយភាពជោគជ័យដូចជាព្រះគ្រិស្ត។*

នៅពេលយើងកើតជាថ្មី ហើយព្រះវិញ្ញាណដ៏វិសុទ្ធសង់ដំណាក់ទ្រង់នៅក្នុងជីវិតរបស់យើង យើងឃើញថា យើងមាននិស្ស័យពីរយ៉ាង ៖ និស្ស័យមួយទាក់ទងជាមួយនឹងនិស្ស័យខាងឯធម្មជាតិ ឬ រូបកាយ ហើយមួយទៀតទាក់ទងជាមួយនឹងនិស្ស័យខាងឯវិញ្ញាណ។ យើងឃើញថា ខ្លួនប្រាណរបស់យើងនៅតែទទួលរងសេចក្ដីល្បួងខាងឯសាច់ឈាម។ នៅលំបាកដែលយើងឆ្លងកាត់ រវាងការល្អ និងការអាក្រក់ដែលមាននៅក្នុងយើង គឺត្រូវបានរៀបរាប់យ៉ាងលំអិតនៅក្នុងគម្ពីររ៉ូមជំពូកទី៧ ។ លោកប៉ូលបានមានប្រសាសន៍ថា៖ " ដ្បិតខ្ញុំដឹងថា អ្វីៗដែលល្អមិនស្ថិតនៅក្នុងខ្ញុំទេ ពោលគឺមិនស្ថិតនៅក្នុងខ្ញុំដែលមាននិស្ស័យលោកីយ៍ទេ(និស្ស័យសាច់ឈាម)។ ខ្ញុំមានឆន្ទៈនឹងធ្វើអំពើល្អ តែខ្ញុំគ្មានសមត្ថភាពនឹងប្រព្រឹត្តអំពើល្អបានឡើយ" (គម្ពីររ៉ូម ៧:១៨) ។ នៅត្រង់នេះលោកសាវ័កប៉ូលមិនបាននិយាយទាក់ទងនឹងជំនួយរបស់ព្រះវិញ្ញាណនោះទេ ប៉ុន្តែនៅក្នុងជំពូកទី៨ លោកបាននិយាយអំពីព្រះវិញ្ញាណដ៏វិសុទ្ធចំនួន១៩ ដង ភ្ជាប់

ជាមួយនឹងជីវិតដែលប្រកបដោយភាពជោគជ័យ។ ច្បាប់របស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងជីវិតគ្រិស្ដបរិស័ទគឺជាអាថ៌កំបាំងក្នុងការយកឈ្នះលើអំពើបាបបាន។ ព្រះវិញ្ញាណបានលះបង់ខ្លាំងណាស់ ចំពោះការអភិវឌ្ឍខាងឯវិញ្ញាណរបស់យើង ទ្រង់សព្វព្រះហឫទ័យបង្ហាញយើងពីរបៀបជំនះលើនិស្ស័យដ៏អាត្មានិយមរបស់យើង (គម្ពីររ៉ូម ៨:១-១៤)។

ទីកន្លែង និង ភាពសំខាន់នៅក្នុងជីវិតរបស់យើង ដែលយើងថ្វាយទៅកាន់ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជាកត្តាកំណត់លក្ខណសម្បត្តិរបស់យើង។ មនុស្សមិនកើតមកជាមួយនឹងទម្លាប់មួយជាក់លាក់នោះទេ។ លក្ខណសម្បត្តិ គឺជាលទ្ធផលដែលបានមកពីទម្លាប់ដែលយើងបង្កើតឡើងដោយទង្វើដែលធ្វើម្តងហើយម្តងទៀត។ លក្ខណសម្បត្តិនៃបុគ្គលនៃរូបកាយ ដែលរស់នៅដើម្បីតែបំពេញចំណង់ខាងឯរូបកាយរបស់ខ្លួនឯង គឺជារូបភាពមួយដែលគួរឲ្យខ្ពើមរអើម និង គួរឲ្យអាណិតខ្លាំងណាស់។ លក្ខណសម្បត្តិនៃបុគ្គលខាងវិញ្ញាណ ដែលអនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ ដឹកនាំជីវិតរបស់គាត់ គឺខុសគ្នាស្រឡះ ដូចដែលយើងនឹងឃើញ។ ដំណោះស្រាយដែលលោកប៉ូលបានផ្តល់ឲ្យគឺថា ៖ "ចូររស់នៅអោយស្របតាមព្រះវិញ្ញាណ នោះបងប្អូននឹងមិនបំពេញតាមបំណងចិត្តលោភលន់របស់និស្ស័យលោកីយ៍ទៀតឡើយ" (គម្ពីរកាឡាទី ៥:១៦)។

៦. *ព្រះវិញ្ញាណដ៏វិសុទ្ធបង្កើតផលផ្លែពេញដោយព្រះពរ នៅក្នុងជីវិតរបស់គ្រិស្តបរិស័ទ។*

មិត្តម្នាក់បានសួរមកខ្ញុំថា ហេតុអ្វីបានជាក្រុមអ្នកដែលថ្លែងថាខ្លួនមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ បានអួតប្រាប់អ្នកដទៃអំពីរឿងខាងវិញ្ញាណរបស់ពួកគេទៅវិញ។ គាត់បាននិយាយថា គាត់មិនអាចនឹកស្រម៉ៃថាព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការអួតបំប៉ោងយ៉ាងនេះអំពីទ្រង់យ៉ាងដូច្នេះទេ។ ខ្ញុំបានយល់ស្របជាមួយគាត់ទាំងស្រុង ។ ដើម្បីជៀសផុតពីបំណងខាងឯសាច់ឈាម (ការចុះចូលជាមួយនឹងចំណង់ខាងសាច់ឈាម) ឬ ជីវិតខាងវិញ្ញាណមិនត្រឹមត្រូវ យើងត្រូវតែដើរជាមួយព្រះវិញ្ញាណ។

ការដើរជាមួយនឹងព្រះវិញ្ញាណ បង្ហាញថាបុគ្គលម្នាក់នោះពឹងផ្អែកលើទ្រង់គ្រប់ពេល និង ជឿលើសមត្ថភាពរបស់ទ្រង់ ក្នុងការប្រទានឲ្យមានការប្រោសលោះនៅក្នុងគ្រប់ផ្នែកនៃជីវិតរបស់បុគ្គលនោះ។ ខណៈពេលដែលយើងមិនបានទទួលការសន្យាថានឹងមានជីវិតដែលមានភាពឥតខ្ចោះគ្មានបាប យើងនឹងទទួលបានការកែប្រែយ៉ាងអស្ចារ្យ នៅពេលណាដែលយើងមានពេញដោយព្រះវិញ្ញាណ និង ត្រូវបានគ្រប់គ្រងដោយព្រះវិញ្ញាណ។ ជំនួសឲ្យការសម្ដែងបង្ហាញពីកិច្ចការខាងឯសាច់ឈាម (គម្ពីរកាឡាទី ៥:១៩-២១) យើងបង្កើតបានជាផលផ្លែរបស់ព្រះវិញ្ញាណវិញ "សេចក្ដីស្រឡាញ់ អំណរ សេចក្ដីសុខសាន្តចិត្តអត់ធ្មត់ ចិត្តសប្បុរស ចិត្តសន្ដោស មេត្តា ជំនឿ ចិត្តស្លូតបូត ចេះទប់ចិត្តខ្លួនឯង" (គម្ពីរកាឡាទី ៥:២២-២៣) ។ គុណសម្បត្តិ ឬ ផលផ្លែទាំងនេះ គឺជាលក្ខណសម្បត្តិរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងគឺពិនិត្យឲ្យបានជាក់ច្បាស់ទៅលើឥរិយាបថ ទំនាក់ទំនង និង សកម្មភាពរបស់យើង ដើម្បីឲ្យឃើញថា ចំណុចទាំងនោះរបស់យើងបានព៌ណនាពីលក្ខណសម្បត្តិទាំងនេះ ឬ បង្ហាញពីកង្វះខាតផលផ្លែទាំងនេះ ។ (សម្រាប់ការសិក្សាបន្ថែមអំពីផលផ្លែនៃព្រះវិញ្ញាណទាំងនេះ សូមមើលនៅក្នុងវគ្គសិក្សាការបម្រើរបស់គ្រិស្តបរិស័ទរបស់សាកលវិទ្យាល័យគ្លូបល ដែលមានចំណងជើងថា៖ *ការរស់នៅដ៏ពេញបរិបូរណ៍ - ការសិក្សាអំពីលក្ខណសម្បត្តិរបស់គ្រិស្តបរិស័ទ។)*

# លំហាត់អនុវត្តន៍

៨ ចូរបកស្រាយរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធជួយអ្នកជឿ ដោយផ្អែកទៅលើពាក្យទាំងប្រាំមួយនៅខាងក្រោមនេះ។

ក) កំណើតថ្មី

ខ) សក្ខីភាព

គ) ការបង្រៀន

ឃ) ការទូលអង្វរជំនួស

ង) ការនាំផ្លូវ

ច) ផលផ្លែ

## ការជ្រមុជរបស់ទ្រង់

វត្ថុបំណងទី៥. *ស្គាល់ពីពាក្យផ្សេងៗទាក់ទងនឹងការជ្រមុជនឹងព្រះវិញ្ញាណ។*

ទំនាក់ទំនងដ៏ស្និតរមួតរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ជាមួយនឹងអ្នកជឿត្រូវបង្ហាញឲ្យឃើញនៅក្នុងព្រះគម្ពីររួមជាមួយនឹងពាក្យរៀបរាប់ជាច្រើន។ ក្នុងនោះមានពាក្យមួយដែលគេហៅថា *ការជ្រមុជ* ដូចយើងបានឃើញពីខាងលើមក ដែលមានន័យថា"ការមុជចុះ"(គម្ពីរម៉ាថាយ ៣:១១ គម្ពីរកិច្ចការ ១:៥)។ តើមានរឿងអ្វីកើតឡើងនៅពេលដែលមនុស្សមុជចុះទៅក្នុងទឹក? ពួកគេនឹងទទឹកសព្វទាំងអស់! ទឹកគឺនៅពេញលើខ្លួនរបស់គេ។ នេះគឺពិតជារឿងមួយដែលអស្ចារ្យណាស់ ដែលយើងដឹងថា មនុស្សធម្មតាដូចយើងអាចត្រូវបានព្រះជាម្ចាស់ចាក់បង្ហូរអង្គទ្រង់យ៉ាងជោកជាំមកលើយើងរាល់គ្នា (បំពេញយើងយ៉ាងពេញលេញ)!

ពាក្យមួយទៀតដែលត្រូវបានប្រើដើម្បីរៀបរាប់អំពីទំនាក់ទំនងមនុស្សជាមួយនឹងព្រះវិញ្ញាណ គឺពាក្យថា *បំពេញ* (គម្ពីរកិច្ចការ ២:៤; ៤:៣១)។ នៅពេលដែលចានពេញ វាគ្មានលទ្ធភាពទទួលអ្វីបានទៀតនោះទេ។ តាមរបៀបដូចគ្នានេះដែរ ព្រះវិញ្ញាណដ៏វិសុទ្ធ សព្វព្រះហឫទ័យប្រទានឫទ្ធានុភាព និង សិរីរុងរឿងរបស់ទ្រង់មកឲ្យយើងយ៉ាងច្រើន ដល់យើងមិនអាចទទួលអ្វីទៀតបាន។ បន្ទាប់មកយើងនឹងមានឫទ្ធានុភាព ប្រាជ្ញាញាណ និង ការចាត់តាំងដែលចាំបាច់សម្រាប់ផ្គាប់ព្រះទ័យព្រះជាម្ចាស់ និង បម្រើទ្រង់យ៉ាងមានប្រសិទ្ធិភាពនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត។ យើងអាចពោរពេញដោយព្រះវិញ្ញាណ ម្ដងហើយម្ដងទៀតទៅតាមពេលវេលា ដូចដែលគ្រិស្តបរិស័ទនៅជំនាន់មុខទទួលដែរ។ នៅពេលដែលសមត្ថភាពរបស់យើងកាន់តែរីកចម្រើនឡើង ទ្រង់នឹងបន្តបំពេញយើងឲ្យកើនទៅកម្រិតថ្មីមួយ ជាមួយនឹងភាពពេញបរិបូរណ៍របស់ទ្រង់។ អ្នកជឿបានទទួលការដាស់តឿនយ៉ាងដូច្នេះថា៖ "ត្រូវអោយបានពោរពេញដោយព្រះវិញ្ញាណ។" (គម្ពីរអេភេសូ ៥:១៨) ។ សូមឲ្យយើងប៉ងប្រាថ្នា ថានឹងបាននៅតែពេញដោយព្រះវិញ្ញាណ!

របៀបទីបីដែលយើងអាចមើលទៅលើទំនាក់ទំនងនេះ គឺការនិយាយថា ព្រះវិញ្ញាណបាន*ចាក់បង្ហូរ*មកលើយើងរាល់គ្នា (គម្ពីរយ៉ូអែល ២:២៨-២៩) ។ លោកយ៉ូអែលបាននិយាយអំពីភ្លៀងធ្លាក់នៅសរទរដូវដែលកសិករសាសន៍អ៊ីស្រាអែលទន្ទឹងរង់ចាំយ៉ាងព្រួយចិត្ត ជាភ្លៀងដែលអាចនឹងជួយដំណាំរបស់ពួកគេ

ឲ្យរីកលូតលាស់បានពេញលេញដល់ពេលច្រូតកាត់។ សូមឲ្យយើងមានបំណងចិត្តយ៉ាងឆេះឈ្ងួលដូចគ្នានេះ ទៅលើការចាក់បង្ហូរនៃព្រះវិញ្ញាណដ៏វិសុទ្ធមកលើក្រុមជំនុំរបស់យើង និង ជីវិតរបស់យើង ដើម្បីឲ្យយើងអាចបង្កើននូវលទ្ធភាពទាំងអស់ដែលយើងមាន ដើម្បីចែកចាយសិរីរុងរឿងរបស់ព្រះជាម្ចាស់។

គម្ពីរសម្ព័ន្ធមេត្រីថ្មី បង្ហាញថាដើម្បីឲ្យកិច្ចការពិសេសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធអាចចាប់ផ្តើមនៅក្នុងជីវិតរបស់យើង ដូចដែលបានបង្ហាញដោយពាក្យដែលខ្ញុំទើបតែបានបង្ហាញខាងលើនេះ យើងត្រូវមានពិសោធដំបូងមួយជាមុនសិន។ គម្ពីរកិច្ចការ ជំពូក២ប្រាប់យើងអំពីការចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធជាលើកដំបូង ដូចនៅការបំពេញសេចក្តីទំនាយរបស់លោកយ៉ូអែល (២:២៨-៣២)។ បទគម្ពីរបានកត់ត្រាអំពីវត្តមានអស់អ្នកដែលបានស្តាប់យល់ពួកសាវ័កនៅពេលដែលពួកគាត់បាននិយាយភាសាផ្សេងៗខុសគ្នា។ ព្រះវិញ្ញាណបានផ្តល់អំណាចឲ្យពួកសាវ័ក និងអ្នកដទៃទៀតបង្ហាញឲ្យឃើញថាពួកគេនិយាយភាសាទាំងនោះ ទោះបីជាពួកគេមិនមែនជាជនជាតិដូចគ្នាក៏ដោយ។ ជាលទ្ធផល អ្នកជឿលើបុណ្យថ្ងៃទីហាសិបជាច្រើននាក់ ជឿថាភស្តុតាងជាក់ស្តែងនៃការជ្រមុជនៅក្នុងព្រះវិញ្ញាណលើកដំបូង គឺជាការនិយាយភាសាដទៃ (ឧទាហរណ៍៖ ភាសាដែលមិនបានមកពីការរៀននេះទេ ប៉ុន្តែបានមកពីការជំរុញពីព្រះវិញ្ញាណដ៏វិសុទ្ធវិញ)។ ការឆ្លងកាត់របស់បុគ្គលនៅក្នុងការជ្រមុជនៅក្នុងព្រះវិញ្ញាណជាលើកដំបូងនេះ មិនគួរត្រូវបានចាត់ទុកជាចំណុចកំពូលបំផុត(នៃបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ ប៉ុន្តែជាការចាប់ផ្តើមនៃដំណើររួមជាមួយព្រះវិញ្ញាណវិញ។

ចាប់ផ្តើមពីបទពិសោធន៍ដែលអ្នកជឿបានឆ្លងកាត់នៅក្នុងកំណត់ត្រាគម្ពីរកិច្ចការ យើងដឹងថាបន្ទាប់ពីការជ្រមុជជាលើកដំបូងនោះ (គម្ពីរកិច្ចការ ២) ពួកគេបានទទួលការបំពេញបន្ថែមទៀត (គម្ពីរកិច្ចការ ៤:៣១)។ បន្ទាប់ពីបានចាប់ផ្តើមជីវិតនៅក្នុងព្រះវិញ្ញាណ ពួកគេបានដើរជាមួយទ្រង់ នឹងលូតលាស់ខាងឯវិញ្ញាណ។ ឧទាហរណ៍ ចូរប្រៀបធៀប គម្ពីរ២កូរិនថូស ៣:១៨ គម្ពីររ៉ូម ៨:២៩ និង គម្ពីរ២ពេត្រុស ៣:១៨)។ ទំនាក់ទំនងនេះ គួរតែកាន់តែស្រស់ត្រកាលជារៀងរាល់ថ្ងៃ។ យើងគួរឃើញពីការលូតលាស់ខាងឯវិញ្ញាណដ៏ជាក់ស្តែង កាលដែលពេលវេលាកាន់តែរំកិលទៅមុខ។ បន្ទាប់ពីបានចាប់ផ្តើមកិច្ចការដ៏ល្អជាមួយយើង ព្រះវិញ្ញាណដ៏វិសុទ្ធនឹងបន្តកិច្ចការនេះរហូតដល់ទីបញ្ចប់ ស្របពេលដែលយើងដើរជាមួយទ្រង់ (គម្ពីរភីលីព ១:៦)។

## *លំហាត់អនុវត្តន៍*

៩ ចូរបំពេញប្រយោគខាងក្រោម ដោយបំពេញពាក្យស័ក្តិសមនឹងការរៀបរាប់ ដែលបានផ្តល់ជូននៅខាងក្រោមនេះនៅក្នុងចន្លោះបន្ទាត់ ៖ *ការជ្រមុជ ការបំពេញ ការចាក់បង្ហូរ*

ក) តាមការទតឃើញរបស់ព្រះជាម្ចាស់ ការជ្រមុជនៅក្នុងព្រះវិញ្ញាណគឺចាត់ទុកជា............។

ខ) អ្នកជឿដែលមិនបានជ្រមុជ ដែលស្វែងរកជំហានដំបូងទៅក្នុងជីវិតជាមួយព្រះវិញ្ញាណ ត្រូវការ.........................នៃព្រះវិញ្ញាណ។

គ) កត្តាមួយដែលសំដៅទៅលើសមត្ថភាពរបស់អ្នកសម្រាប់ទទួលព្រះវិញ្ញាណ គឺ..............
.......................។

## និមិត្តសញ្ញារបស់ទ្រង់

**វត្ថុបំណងទី៦.** *ប្រាប់ពីរបៀបដែលអ្នកអាចយក ផ្ទត់គំនិតដែលនិមិត្តសញ្ញានីមួយនៃវិញ្ញាណតំណាងឲ្យ ទៅប្រើប្រាស់នៅក្នុងជីវិតរបស់យើង ដើម្បីឲ្យអ្នកអាចបម្រើព្រះអម្ចាស់បានប្រសើរជាងមុន។*

យើងមិនអាចធ្វើការសន្និដ្ឋានការសិក្សានេះនៅលើគោលលទ្ធិអំពីព្រះវិញ្ញាណដ៏វិសុទ្ធទៅចំពោះអ្នកជឿដោយមិនបាននិយាយអំពីនិមិត្តសញ្ញានៅក្នុងព្រះគម្ពីរដែលរៀបរាប់ពីផ្នែកខ្លះៗនៃកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនោះទេ។ ចូរបើកមើលខគម្ពីរខាងក្រោមនេះ ដើម្បីឃើញពីរបៀបដែលនិមិត្តសញ្ញាទាំងនេះត្រូវបានគេយកទៅប្រើប្រាស់។

| **ខគម្ពីរ** | **និមិត្តសញ្ញា** | **ការរៀបរាប់** |
|---|---|---|
| ១. គម្ពីរម៉ាថាយ ៣:១១ | ភ្លើង | ភ្លើងដុតកំទេចអ្វីដែលមិនបរិសុទ្ធ |
| ២. គម្ពីរម៉ាថាយ ៣:១៦ | សត្វព្រាប | សត្វព្រាបតំណាងឲ្យភាពទន់ភ្លន់ |
| ៣. គម្ពីរ១ពង្សាវតារក្សត្រ១៩:១៦<br>គម្ពីរ១យ៉ូហាន ២:២០ | ប្រេងតាំង<br>ការចាក់ប្រេងតាំងដោយព្រះវិញ្ញាណដ៏វិសុទ្ធ | ស្តេច និង ព្យាការីនៅក្នុងសម្ព័ន្ធមេត្រីចាស់តែងតែត្រូវបានចាក់ប្រេងប្រសិទ្ធិពរឲ្យ ជាសញ្ញាសំគាល់អំពីការអនុញ្ញាតរបស់ព្រះអម្ចាស់ក្នុងកិច្ចការរបស់ពួកគេ។ |
| ៤. គម្ពីរលូកា ១១:១៣ | ព្រះអំណោយទាន | ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាព្រះអំណោយទានរបស់ព្រះវរបិតាមកកាន់យើង។ |
| ៥. គម្ពីរយ៉ូហាន ៧:៣៧-៣៩ | ទន្លេដែលមានទឹកផ្តល់ជីវិត | ព្រះវិញ្ញាណដ៏វិសុទ្ធបំពេញយើងឲ្យបានហូរហៀរជាមួយនឹងជីវិតថ្មី។ |
| ៦. គម្ពីរ២កូរិនថូស ១:២២<br>គម្ពីរអេភេសូ ១:១៣-១៤ | ត្រា ឬ ការបញ្ចាំចិត្ត | ព្រះវិញ្ញាណដ៏វិសុទ្ធត្រូវប្រទានមកដើម្បីធានាអំពីជីវិតអស់កល្បជានិច្ចរបស់យើងជាមួយព្រះវរបិតា។ |
| ៧. គម្ពីរយ៉ូហាន២០:២២<br>គម្ពីរអេសេគាល ៣៧:៩, ១៤ | ខ្យល់ដង្ហើម<br>ខ្យល់ | ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាខ្យល់ដង្ហើមរបស់ព្រះជាម្ចាស់ដែលប្រទានជីវិតមកឲ្យយើង។ |

## *លំហាត់អនុវត្តន៍*

១០ ចូរសរសេររៀបរាប់និមិត្តសញ្ញាទាំងអស់ជាចំណុចៗ នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។ ថ្លែងពីរបៀបដែលអ្នកអាចយកគំនិតសំខាន់ដែលនិមិត្តសញ្ញានីមួយៗតំណាងឲ្យ ទៅប្រើប្រាស់នៅក្នុងជីវិតរបស់អ្នក ដើម្បីឲ្យអ្នកអាចបម្រើព្រះអម្ចាស់បានកាន់តែប្រសើរឡើង។ លំហាត់នេះនឹងជួយអ្នកឲ្យរកឃើញពីសេចក្តីពិតខ្លះ អំពីកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងជីវិតរបស់អ្នក និង អំណោរដែលបានមកតាមរយៈទ្រង់។

## ទាក់ទងនឹងក្រុមជំនុំ

**វត្ថុបំណងទី៧.** *រៀបរាប់ពីការផ្តល់អំណាចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ សម្រាប់ការបម្រើ និង ការឆ្លើយតបរបស់អ្នកជឿទៅនឹងការផ្តល់អំណាចនេះ។*

ការពិភាក្សារបស់យើងអំពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធ ដឹកនាំពិភពលោកនៃអ្នកមិនជឿ និង អ្នកជឿ ផ្តល់ឲ្យយើងនូវមូលដ្ឋានសម្រាប់ការមើលទៅកាន់ព័ន្ធកិច្ចរបស់ទ្រង់ចំពោះព្រះកាយរបស់ព្រះគ្រិស្តទុកជាសមាគម និង ក្រុមមួយ។

នៅក្នុងជំនាន់សម្ព័ន្ធមេត្រីចាស់ មនុស្សរបស់ព្រះជាម្ចាស់ទទួលបានផលប្រយោជន៍យ៉ាងច្រើន ពីព័ន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ នៅពេលដែលទ្រង់បានចាត់តាំងមនុស្សដែលត្រូវបានជ្រើសរើសសម្រាប់ការបម្រើជាពិសេស។ ទោះជាយ៉ាងណា នៅក្នុងសម័យសម្ព័ន្ធមេត្រីថ្មី ព័ន្ធកិច្ចនេះគឺកាន់តែបង្ហាញឲ្យឃើញច្បាស់ ដ្បិតព័ន្ធកិច្ចនៅតែបន្តទៅមុខ និង គ្មានការកំណត់សម្រាប់ក្រុមអ្នកជឿពិសេសណាមួយទេ។ សូមមើលពីរបៀប និង មូលហេតុដែលព័ន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងជំនាន់សម្ព័ន្ធមេត្រីថ្មី មានភាពខុសគ្នាពីកិច្ចការរបស់ទ្រង់នៅក្នុងសម័យសម្ព័ន្ធមេត្រីចាស់។

នៅក្នុងព្រឹត្តិការណ៍នៃការជ្រមុជទឹករបស់ព្រះយេស៊ូ លោកយ៉ូហានបាទីស្តបានប្រកាសថាព្រះយេស៊ូជាព្រះដែលនឹងជ្រមុជពួកគេនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីរយ៉ូហាន ១:៣៣) ។ ជាលទ្ធផលដែលបានមកពីកិច្ចការប្រោសលោះរបស់ទ្រង់ ព្រះយេស៊ូបានបើកផ្លូវដើម្បីឲ្យអ្នកជឿបានជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ និង ទទួលបានព្រះដ៏ជួយការពារ។ ព្រះវិញ្ញាណដ៏វិសុទ្ធ គឺជាអ្នកតំណាងផ្ទាល់របស់ព្រះយេស៊ូដែលនឹងមកគង់ជាមួយពួកគេជារៀងរហូត (គម្ពីរយ៉ូហា១៤:១៦)។ បន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូបានមានព្រះបន្ទូលប្រាប់ទៅពួកសាវ័ករបស់ទ្រង់ថា ពួកគេនឹងត្រូវបានជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ នៅប៉ុន្មានថ្ងៃទៀត ហើយជាលទ្ធផលពួកគេក៏បានទទួលឫទ្ធានុភាព(គម្ពីរកិច្ចការ១:៥,៨)។

ផ្ទុយពីការចាត់តាំងពិសេសសម្រាប់ការងារជាក់លាស់ណាមួយ ដូចនៅក្នុងសម័យសម្ព័ន្ធមេត្រីចាស់ បទពិសោធន៍ថ្មីនៃការជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនេះ គឺជាការផ្តល់អំណាចជាមូលដ្ឋានសម្រាប់អ្នកជឿ ដើម្បីឲ្យមានជីវិត និង ការបម្រើ ដ៏ជាប់លាប់ និង មានប្រសិទ្ធិភាព។ ព្រះវត្តមានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធមិនមែនកម្រិតត្រឹមការសម្រេចកិច្ចការជាក់លាក់ណាមួយ ឬ ឱកាស (ពេលវេលា) ជាក់លាក់ណាមួយ ដូចនៅក្នុងសម័យសម្ព័ន្ធមេត្រីចាស់នោះទេ។ ផ្ទុយទៅវិញ ទ្រង់នឹងគង់នៅជារៀងរហូតនៅ

ក្នុងអស់អ្នកដែលទទួលព្រះគ្រិស្ត (គម្ពីរយ៉ូហាន ៧:៣៨-៣៩; ១៤:១៧)។ លទ្ធផលនៃព្រះវត្តមានដែលគង់នៅក្នុងយើង និង ប្រកបដោយឫទ្ធានុភាពថ្មីនេះ គឺជាការរីកចម្រើនដែលគួរឲ្យគាប់ចិត្តមួយ នៅពេលដែលអ្នកដើរតាមព្រះយេស៊ូ ចែករំលែកជំនឿ និង បទពិសោធន៍របស់គេ ជាមួយអ្នកដទៃ។

ដូច្នេះ ក្នុងបទពិសោធន៍ជាមួយនឹងគម្ពីរសម្ព័ន្ធមេត្រីថ្មី អ្នកជឿអាចទទួលបានព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅក្នុងពួកគេ ផ្តល់អំណាចឲ្យពួកគេដើម្បីរស់នៅក្នុងជីវិតដ៏វិសុទ្ធ និង បម្រើព្រះជាម្ចាស់ដោយស្ម័គ្រចិត្ត។ ពួកគេលែងចាំបាច់ត្រូវរស់នៅតាមក្រឹត្យវិន័យ (ច្បាប់) ណាមួយដូចនៅក្នុងជំនាន់សម្ព័ន្ធមេត្រីចាស់ដោយគ្មានការផ្តល់អំណាចដើម្បីបំពេញតាមការកំណត់របស់ច្បាប់នោះទេ មានតែបំណងល្អរបស់ពួកគេតែប៉ុណ្ណោះ។ នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅក្នុងសមជិកក្រុមជំនុំ និង ដឹកនាំសកម្មភាពរួមគ្នារបស់ពួកគេ នោះពួកគេមានសមត្ថភាពក្នុងការធ្វើកិច្ចការ និង ធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅលើផែនដី។

## លំហាត់អនុវត្តន៍

១១ ចូរផ្គូផ្គងកាលបរិច្ឆេទ (ខាងស្តាំ) ទៅជាមួយនឹងការរៀបរាប់អំពីសកម្មភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងជីវិតរបស់មនុស្ស (ខាងឆ្វេង)។ លំហាត់នេះនឹងជួយឲ្យអ្នកបានឃើញពីភាពខុសគ្នារវាងសកម្មភាពរបស់ព្រះវិញ្ញាណនៅក្នុងសម័យសម្ព័ន្ធមេត្រីចាស់ និង សម្ព័ន្ធមេត្រីថ្មី។

.........ក) ការគង់នៅសម្រាប់ព័ន្ធកិច្ចណាមួយបន្ទាប់មកក៏ត្រូវបានដកចេញ។

.........ខ) ការគង់នៅក្នុងអស់អ្នកណាដែលទទួលព្រះគ្រិស្ត។

.........គ) ព្រះវត្តមានរបស់ទ្រង់គឺស្ថិតនៅខាងក្នុង និង មានលក្ខណៈបុគ្គល

.........ឃ) ព្រះវត្តមានរបស់ទ្រង់ស្ថិតនៅខាងក្រៅ និង គ្មានលក្ខណៈជាបុគ្គល

.........ង) មនុស្សដែលបានជ្រមុជនៅក្នុងព្រះវិញ្ញាណតាមរយៈការទទួលទ្រង់។

.........ច) ការចាក់ប្រេងតាំងមនុស្សណាម្នាក់ទៅតាមពេលវេលាណាមួយ និងសម្រាប់មូលហេតុពិសេស

១) គម្ពីរសម្ព័ន្ធមេត្រីចាស់

២) គម្ពីរសម្ព័ន្ធមេត្រីថ្មី។

---

អ្នកដើរតាមព្រះយេស៊ូមិនត្រឹមតែទទួលបានអំណាច ឲ្យធ្វើ*សក្ខីភាព* យ៉ាងមានប្រសិទ្ធិភាពប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ទទួលបានកម្លាំងប្រកបដោយភាពជោគជ័យ ដើម្បី*ការពារ* ដំណឹងល្អ។ នេះគឺជាការសម្រេចបានដោយផ្ទាល់នៃគម្ពីរម៉ាកុស១៣:៩-១១។ ដំបូងឡើយ លោកពេត្រុសគ្មានកម្លាំងដើម្បីការពារទំនាក់ទំនងរបស់លោកជាមួយព្រះយេស៊ូនោះទេ (គម្ពីរម៉ាថាយ ២៦:៦៩-៧៥)។ ទោះជាយ៉ាងណា

បន្ទាប់ពីមានបទពិសោធន៍ពិសេសៗជាច្រើនលើក រួមបញ្ចូលទាំងបានឃើញការមានព្រះជន្មរស់របស់ព្រះយេស៊ូ និង ការបំពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងបុណ្យថ្ងៃទីហាសិប លោកបានទទួលភាពក្លាហានក្នុងការចែកចាយ (គម្ពីរកិច្ចការ ២) និង ភាពក្លាហានក្នុងការផ្តល់ហេតុផលការពារជំនឿរបស់លោក (គម្ពីរកិច្ចការ ៤:៨-២០)។

លើសពីនេះទៅទៀត ព្រះវិញ្ញាណដ៏វិសុទ្ធបានគ្រប់គ្រងបេសកម្មនៃការផ្សាយដំណឹងល្អ របស់ក្រុមជំនុំ ប្រាប់អ្នកបម្រើរបស់ទ្រង់ថា កន្លែងដែលត្រូវទៅ និង កន្លែងណាមិនត្រូវទៅ (គម្ពីរកិច្ចការ ១៣:២; ១៦:៦-៧)។ តាមរយៈការដឹកនាំរបស់ទ្រង់ គ្រិស្តបរិស័ទដំបូង បានទៅដល់តំបន់សំខាន់ៗ ដែលបានក្លាយជាកន្លែងមិនអាចខ្វះបាននៅក្នុងការបន្តបេសកម្មរបស់ក្រុមជំនុំ គឺការចែកចាយដំណឹងល្អទៅដល់ "មនុស្សលោកទាំងអស់" (គម្ពីរម៉ាកុស ១៦:១៥)។ នៅក្នុងបេសកម្មផ្សាយដំណឹងល្អលើកទីមួយ របស់ក្រុមជំនុំ ព្រះវិញ្ញាណដ៏វិសុទ្ធបានញែកលោកប៉ូល និង លោកបារណាបាស សម្រាប់ការបម្រើ និង ចាត់តាំងពួកលោកសម្រាប់ព័ន្ធកិច្ច (គម្ពីរកិច្ចការ ១៣:២)។

ព្រះវិញ្ញាណដ៏វិសុទ្ធ ក៏បានដឹកនាំនៅក្នុងកិច្ចការគ្រប់គ្រងពិតជាក់ស្តែងរបស់ក្រុមជំនុំដែរ។ នៅពេលដែលក្រុមជំនុំបានលូតលាស់ និង បានឆ្លងកាត់ដែនកំណត់របស់ជាតិសាសន៍ វប្បធម៌ និង សាសន៍ សំណួរជាច្រើនត្រូវបានលើកឡើងដែលទាមទារចម្លើយដែលស្របទៅតាមបទគម្ពីរ និង សេចក្តីស្រឡាញ់របស់គ្រិស្តបរិស័ទ។ ការប្រកាន់ពូជសាសន៍របស់មនុស្សលោក បានគំរាមកំហែងបែងចែកព្រះកាយរបស់ព្រះគ្រិស្ត ប៉ុន្តែដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធបានផ្តល់អំណាចឲ្យលោកយ៉ាកុប និង ពួកសាវ័កដើម្បីដោះស្រាយបញ្ហាលំបាក និង ដើម្បីផ្តល់ការប្រឹក្សាដ៏ឈ្លាសវៃ (គម្ពីរកិច្ចការ ១៥:២៨-២៩)។ ការនេះបានអនុញ្ញាតឲ្យក្រុមជំនុំលូតលាស់ កាន់តែលឿន និង បង្កើតបានជាការរួបរួមខាងឯវិញ្ញាណមួយ។

តាមរយៈការដឹកនាំបន្តបន្ទាប់របស់ទ្រង់ ព្រះវិញ្ញាណដ៏វិសុទ្ធបាននាំលោកប៉ូល និង អ្នកដទៃទៀតឲ្យផ្តល់ការលើកទឹកចិត្ត ការកំសាន្តចិត្ត សេចក្តីបង្រៀនពីគោលលទ្ធិ ការព្រមាន និង ការដាក់បញ្ញត្តិទៅដល់ក្រុមជំនុំតាមរយៈសំបុត្រដែលមានការជំរុញពីព្រះវិញ្ញាណ។ ឧទាហរណ៍ លោកប៉ូលបានដោះស្រាយជាមួយនឹងសំណួរពិសេសអំពីឥរិយាបថនៅក្នុងក្រុមជំនុំក្រុងកូរិនថូស ទាក់ទងនឹងទំនួលខុសត្រូវនៅក្នុងសង្គម (គម្ពីរ១កូរិនថូស ៧:៤០)។ អ្នកសរសេរសំបុត្រទៅកាន់សាសន៍ហេប្រឺបានបកស្រាយពីវិន័យ ថាជាដំណើរការនៅការលូតលាស់ ដែលតាមរយៈការលូតលាស់នេះព្រះជាម្ចាស់ដឹកនាំអ្នកជឿឆ្ពោះទៅភាពពេញវ័យខាងឯវិញ្ញាណរបស់ពួកគេ (គម្ពីរហេប្រឺ ១២:៤-១១)។

នៅក្នុងដំណើរការជំពេញវ័យ ព្រះវិញ្ញាណដ៏វិសុទ្ធដែលជាអ្នកគ្រប់គ្រងប្រកបដោយប្រាជ្ញាញាណទ្រង់បានបំពាក់បំប៉នអ្នកជឿជាមួយនឹងព្រះអំណោយទានដែលចាំបាច់នៅក្នុងការធ្វើតាមតួនាទីរបស់ពួកគេ នៅក្នុងពិភពលោក និងនៅក្នុងក្រុមជំនុំដែលជាព្រះកាយរបស់ព្រះគ្រិស្ត។ (ចូរប្រៀបធៀប គម្ពីររ៉ូម ១២:៤-៨ គម្ពីរ១កូរិនថូស១២:១-២៨ និង គម្ពីរអេភេសូ ៤:១១-១៦)។ លោកប៉ូលមានប្រសាសន៍ថា៖ "មានសកម្មភាពផ្សេងៗពីគ្នា តែមានព្រះជាម្ចាស់តែមួយព្រះអង្គទេ ដែលបំពេញសកម្មភាពទាំងនោះ នៅក្នុងមនុស្សទាំងអស់។ ព្រះវិញ្ញាណប្រោសប្រទានអោយម្នាក់ៗសំដែងព្រះអំណោយទាន ដើម្បីជាប្រយោជន៍រួម" (គម្ពីរ១កូរិនថូស ១២:៦-៧)។

ដូច្នេះព្រះវិញ្ញាណដ៏វិសុទ្ធប្រទានកម្លាំងទាំងនេះទៅកាន់អ្នកជឿៈ

១. ឫទ្ធានុភាពដើម្បីផ្សព្វផ្សាយដំណឹងល្អ។

២. ប្រាជ្ញាញាណ និង កម្លាំងចិត្តដែលចាំបាច់ក្នុងការការពារជំនឿ

៣. ព្រះអំណោយទានសមរម្យដើម្បីបម្រើព្រះកាយរបស់ព្រះគ្រិស្តទាំងមូល និង សម្រាប់សមាជិកម្នាក់ៗផងដែរ។

៤. ការដឹកនាំរបស់មនុស្ស ដើម្បីដឹកនាំកិច្ចការបម្រើ

៥. និមិត្ត និង ការជំរុញចិត្តដែលចាំបាច់ក្នុងការបំពេញតាមមហាបេសកកម្ម។

## *លំហាត់អនុវត្តន៍*

១២ ចូរផ្គូផ្គងសេចក្ដីរៀបរាប់អំពីព័ន្ធកិច្ចរបស់ព្រះវិញ្ញាណ (ខាងស្ដាំ) ទៅជាមួយនឹងការឆ្លើយតបដែលស័ក្ដិសមនឹងសេចក្ដីរៀបរាប់នោះ (ខាងឆ្វេង)។

.........ក) អ្នកជឿបានដឹង និង មានបំណងចិត្តសម្រាប់ឱកាសដើម្បីឈោងចាប់អ្នកមិនទាន់ជឿ។

.........ខ) អ្នកជឿនៅក្នុងក្រុមជំនុំបំពេញតួនាទីដូចជាខ្លួនមួយ ដែលម្នាក់បំពេញព័ន្ធកិច្ចបម្រើពិសេសរៀងៗខ្លួន។

.........គ) អ្នកជឿទទួលបានអំណាចដើម្បីការពារដំណឹងល្អ។

.........ឃ) អ្នកជឿពឹងផ្អែកលើខគម្ពីរ និង ការអធិស្ឋាននៅពេលពួកគេប្រឈមមុខជាមួយនឹងការលំបាក និង ការសម្រេចចិត្ត។

១) ជះឥទ្ធិពលទៅលើឫទ្ធានុភាពចម្បងសម្រាប់ជីវិត និង ការបម្រើ។

២) ការប្រទានព្រះអំណោយទាន

៣) ការប្រទាននិមិត្ត និង ការដឹកនាំ

៤) ការដោះស្រាយបញ្ហា

៥) ការប្រទានប្រាជ្ញា និង សេចក្ដីក្លាហាន

តើអ្នកឃើញដែរឬទេថា យើងត្រូវពឹងផ្អែកលើព្រះវិញ្ញាណដ៏វិសុទ្ធខ្លាំងប៉ុនណា នៅលើជីវិតខាងឯវិញ្ញាណ កម្លាំង និមិត្ត ប្រសិទ្ធិភាពនៅក្នុងការបម្រើ ជំនួយនៅពេលជួយការល្បួងល និង ការធ្វើការសម្រាប់ជ័យជំនះ និង ភាពពេញវ័យផ្ទាល់ខ្លួនរបស់យើង? ចូរថ្វាយបង្គំព្រះវិញ្ញាណដ៏វិសុទ្ធ ។ ចូរស្រឡាញ់ព្រះវត្តមានរបស់ទ្រង់នៅក្នុងជីវិតរបស់អ្នក។ ចូរមានបំណងចិត្តដើម្បីលូតលាស់ និង អភិវឌ្ឍខ្លួនឲ្យទៅជាមនុស្សខាងឯវិញ្ញាណ ដូចដែលទ្រង់សព្វព្រះហឫទ័យសម្រាប់អ្នក។ សូមឲ្យអ្នកតែងតែដឹងជានិច្ចអំពីវត្តមាននៃបុគ្គលខាងឯវិញ្ញាណដែលបានកើតឡើងនៅក្នុងអ្នក ។ សូមឆាប់ទទួលអារម្មណ៍ដឹងពីសម្លេងនៃអង្គបុគ្គលនេះ ឮពីការអង្វររបស់ទ្រង់ ការកែតម្រូវរបស់ទ្រង់ និង ការក្រើនរំលឹកពីទ្រង់។ សូមឲ្យគ្រប់គំនិត ការសន្ទនា និង ទង្វើទាំងអស់របស់អ្នកបានឆ្លុះបញ្ចាំងពីការដឹងនៅក្នុងចិត្តរបស់អ្នក អំពីឋានៈនៃការដឹកនាំរបស់ទ្រង់នៅក្នុងជីវិតរបស់អ្នក។ បន្ទាប់មកមាគ៌ារបស់អ្នក នឹងក្លាយជាការរីកចម្រើនខាងឯវិញ្ញាណ ហើយជីវិតរបស់អ្នកនឹងបានជោគជ័យពិតៗ។

# ការប្រឡងផ្ទាល់ខ្លួន

**ត្រូវ/ខុស។** ចូរសរសេរអក្សរ ត នៅក្នុងចន្លោះបន្ទាត់ ប្រសិនបើប្រយោគណាត្រឹមត្រូវ ។ ប្រសិនបើប្រយោគមិនត្រឹមត្រូវ ចូរសរសេរអក្សរ ខ ។

........១ លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ មានដូចជា ភាពអស់កល្បជានិច្ច សព្វានុភាព សព្វជ្ញភាព(សព្វត្ថិភាព) និង សព្វញ្ញូតភាព ក៏អាចយកទៅប្រើប្រាស់ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធបានដែរ។

.......២ ដូចដែលបានប្រើនៅក្នុងសំណេររបស់លោកប៉ូល ពាក្យថា*ព្រះអម្ចាស់* ដែលនិយាយសំដៅទៅលើព្រះជាម្ចាស់តែមួយគត់ គឺត្រូវបានប្រើប្រាស់ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ។

........៣ ការប្រសិទ្ធិពររបស់ពួកសាវ័ក និង រូបមន្តសម្រាប់ការជ្រមុជ បង្ហាញពីគុណសម្បត្តិដ៏សំខាន់របស់អង្គព្រះនៅក្នុងព្រះត្រៃឯក។

........៤ យោងតាមនិស្ស័យ ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាព្រះ គ្មានភាពជាបុគ្គល ដែលមានលក្ខណៈសម្បត្តិដូចជាខ្យល់។

.........៥ ទង្វើជាបុគ្គល ព្រះនាមជាបុគ្គល ការទាក់ទងជាបុគ្គល សព្វនាមជាបុគ្គល និង ការទទួលទង្វើបែបបុគ្គល គឺជាសមាសភាគ ដែលបញ្ជាក់ប្រាប់យ៉ាងច្បាស់ថា ព្រះវិញ្ញាណដ៏វិសុទ្ធមានបុគ្គលិកលក្ខណៈ។

........៦ ដោយយើងរាល់គ្នាមានកំណត់ ហើយព្រះវិញ្ញាណដ៏វិសុទ្ធគ្មានដែនកំណត់ យើងមិនអាចយល់អ្វីសោះអំពីបុគ្គលិកលក្ខណៈ និង កិច្ចការរបស់ទ្រង់។

........៧ ព្រះវិញ្ញាណដ៏វិសុទ្ធមិនទាក់ទងជាមួយភាពមិនវិសុទ្ធ និង មនុស្សមានបាបនោះទេ។

........៨ អ្នកជឿទទួលបានជំនួយពិសេសពីព្រះវិញ្ញាណដ៏វិសុទ្ធ តាមរយៈការទូលអង្វរជំនួសរបស់ទ្រង់សម្រាប់ពួកគេ។

.........៩ លោកពេត្រុសបានបង្រៀនថា បទពិសោធន៍ផ្ទាល់ខ្លួនរបស់នរណាម្នាក់គឺ អាចទុកចិត្តនៅក្នុងការដឹកនាំជំនឿ និង ការអនុវត្ត ជាជាងព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅទៀត។

........១០ ភាពខុសគ្នាធំបំផុតរវាង ព័ន្ធកិច្ចរបស់ព្រះវិញ្ញាណនៅក្នុងជំនាន់អ៊ីស្រាអែលសម្ព័ន្ធមេត្រីចាស់ និង នៅក្នុងក្រុមជំនុំសម្ព័ន្ធមេត្រីថ្មី គឺថា ទ្រង់បានគង់នៅក្នុងអ្នកជឿនៃសម្ព័ន្ធមេត្រីថ្មី។

........១១ ព័ន្ធកិច្ចរបស់ព្រះវិញ្ញាណគឺ កំណត់នៅត្រឹមការនាំយកដំណឹងល្អទៅកាន់មនុស្ស និង ការពារដំណឹងល្អនៅចំពោះមុខរាជរដ្ឋាភិបាល។

........១២ ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាអ្នកគ្រប់គ្រងដ៏គួរឲ្យទុកចិត្តនៅក្នុងស្ថានភាពដែលមានបញ្ហា។

........១៣ នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធ អាចដឹកនាំអ្នកជឿឆ្ពោះទៅ ជ័យជំនះលើនិស្ស័យបាបរបស់ពួកគេ អ្នកជឿទាំងនោះបានកាន់តែដូចព្រះអម្ចាស់របស់ពួកគេ។

.........១៤ ជីវិតនៅក្នុងព្រះវិញ្ញាណចាប់ផ្ដើមនៅពេលដែលយើងបានពេញដោយព្រះវិញ្ញាណ។

.........១៥ នៅពេលដែលអ្នកជឿទទួលការជ្រមុជនៅក្នុងព្រះវិញ្ញាណ ពួកគេបានចូលទៅដល់ភាពពេញវ័យបរិបូរណ៍ខាងឯវិញ្ញាណ។

.........១៦ ការជ្រមុជនៅក្នុងព្រះវិញ្ញាណ គឺជាគ្រិះមូលដ្ឋាននៃជីវិត និង ការលូតលាស់រីងឆ្ងាយទៅមុខ នៅក្នុងព្រះវិញ្ញាណ។

.........១៧ ព្រះវិញ្ញាណដ៏វិសុទ្ធ ត្រូវបានប្រទានមកកាន់ពួកយើង ទុកជាការធានានៃជីវិតអស់កល្បជានិច្ច ជាមួយព្រះវរបិតា។

..........១៨ ការអភិសេកដោយប្រេង ជាការតំណាងឲ្យភាពបរិសុទ្ធរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

..........១៩ ការជ្រមុជនៅក្នុងព្រះវិញ្ញាណគឺប្រៀបបានទៅនឹងទន្លេនៃទឹកដែលផ្តល់ជីវិត នៅក្នុង បទគម្ពីរ។

..........២០ ការគង់នៅរបស់ព្រះវិញ្ញាណ គឺការធានាថា អ្នកជឿនឹងបានវិសុទ្ធ និង មានប្រសិទ្ធិភាពជា និច្ច។

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១ ក) ៤) ភាពអស់កល្បជានិច្ច

ខ) ៣) សព្វដ្ឋភាព(សព្វត្ថិភាព)

គ) ១) សព្វានុភាព

ឃ) ២) សព្វញ្ញូតភាព

៧ ចម្លើយ ក) គ) និង ឃ) ជាចម្លើយត្រឹមត្រូវ។ ចម្លើយខ) គឺចម្លើយខុស។ (តាមរយៈការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់គ្រិស្ត ទ្រង់បានយកឈ្នះលើសាតាំង។)

២ ចម្លើយ ក) គ) និង ឃ) គឺជាភស្តុតាងអំពីភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។
ចម្លើយ ខ) មិនមែនជាភស្តុតាងបញ្ជាក់ភាពជាព្រះរបស់ទ្រង់នោះទេ ។ ពាក្យថា *ព្រះដ៏ជួយការពារ* គឺជាការរៀបរាប់អំពីតួនាទីមួយនៅក្នុងចំណោមតួនាទីជាច្រើនរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

៨ ចម្លើយរបស់អ្នក គួរតែស្រដៀងចម្លើយខាងក្រោមនេះ៖

ក) តាមរយៈការកើតជាថ្មី ព្រះវិញ្ញាណដ៏វិសុទ្ធ នាំយើងចូលទៅក្នុងគ្រួសាររបស់ព្រះជាម្ចាស់។

ខ) ទ្រង់ប្រទានឫទ្ធានុភាពឲ្យយើងដើម្បីធ្វើសក្ខីភាព។

គ) ទ្រង់បង្រៀនយើង។

ឃ) ទ្រង់អធិស្ឋានទៅកាន់ព្រះវរបិតាជំនួសយើង (ទូលអង្វរសម្រាប់យើង)។

ង) នៅពេលយើងអនុញ្ញាត ទ្រង់នឹងដឹកនាំយើងឆ្ពោះទៅកាន់ភាពជោគជ័យ និង ជីវិតដូចជាព្រះគ្រិស្ត។

ច) ទ្រង់បង្កើតផលផ្លែនៃព្រះវិញ្ញាណ (លក្ខណសម្បត្តិដូចជាព្រះគ្រិស្ត) នៅក្នុងយើង នៅពេលដែលយើងថ្វាយការគ្រប់គ្រងលើជីវិតរបស់យើងទៅដល់ទ្រង់។

៣ ក) ២) កិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅលើផែនដី។

ខ) ៣) អធិបតេយ្យរបស់ព្រះជាម្ចាស់

គ) ៤) ភាពស្មើគ្នានៃអង្គព្រះនៅក្នុងព្រះត្រៃឯកភាពពេញលេញ

ឃ) ១) ពហុភាពនៃអង្គព្រះនៅក្នុងព្រះត្រៃឯកភាពពេញលេញនៅក្នុងការបង្កើតរបស់សព្វសារពើ

ង) ៤) ភាពស្មើគ្នានៃអង្គព្រះនៅក្នុងព្រះត្រៃឯកភាពពេញលេញ

៩ ក) ការចាក់បង្ហូរ

ខ) ការជ្រមុជ

គ) ការបំពេញ

៤ ក) ៣) បំណងព្រះហឫទ័យ

ខ) ១) សតិបញ្ញា

គ) ២) វេទយិតភាព

១០ ចម្លើយរបស់អ្នកអាចស្រដៀងនឹងចម្លើយរបស់ខ្ញុំ៖

**ភ្លើង៖** ព្រះវិញ្ញាណដ៏វិសុទ្ធបន្សុទ្ធខ្ញុំ

**សត្វព្រាប៖** ទ្រង់ដឹកនាំខ្ញុំដោយក្ដីទន់ភ្លន់

**ប្រេងតាំង៖** ព្រះវិញ្ញាណចាត់តាំងខ្ញុំសម្រាប់ការបម្រើដោយមានប្រសិទ្ធិភាព។

**ព្រះអំណោយទាន៖** ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាព្រះអំណោយទានរបស់ព្រះវរបិតាសម្រាប់ខ្ញុំ។

**ទឹកដែលផ្ដល់ជីវិត៖** ទ្រង់បំពេញខ្ញុំឲ្យបានពេញហូរហៀរ ទ្រង់ផ្ដល់ជីវិតឲ្យខ្ញុំ។

**ត្រា ឬ ការបញ្ចាំចិត្ត៖** ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាការធានារបស់ព្រះជាម្ចាស់មកកាន់ខ្ញុំថា ខ្ញុំនឹងទទួលព្រះរាជ្យដ៏អស់កល្បជាមួយទ្រង់។

**ខ្យល់ដង្ហើម និង ខ្យល់៖** ព្រះវិញ្ញាណដ៏វិសុទ្ធប្រទាន (ដង្ហើមនៅក្នុងខ្ញុំ) ជីវិតអស់កល្បជានិច្ច។

៥ សកម្មភាពទាំងនេះបង្ហាញថាទ្រង់បានធ្វើសកម្មភាព ដែលមានតែភាវៈមានភាពជាបុគ្គលតែប៉ុណ្ណោះអាចធ្វើបាន ហើយមិនអាចធ្វើឡើងដោយកម្លាំងអបុគ្គលនោះទេ។ ដូច្នេះហើយ សកម្មភាពទាំងនេះចង្អុលបង្ហាញពី*ភាពជាបុគ្គល*របស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

១១ ក) ១) គម្ពីរសម្ព័ន្ធមេត្រីចាស់

ខ) ២) គម្ពីរសម្ព័ន្ធមេត្រីថ្មី

គ) ២) គម្ពីរសម្ព័ន្ធមេត្រីថ្មី

ឃ) ១) គម្ពីរសម្ព័ន្ធមេត្រីចាស់

ង) ២) គម្ពីរសម្ព័ន្ធមេត្រីថ្មី

ច) ១) គម្ពីរសម្ព័ន្ធមេត្រីចាស់

៦ អ្នកគួរតែបានគូសរង្វង់ជុំវិញចម្លើយទាំងអស់លើកលែងតែចម្លើយ គ) កម្លាំងអបុគ្គល និង ឆ) វា, ចម្លើយទាំងពីរនេះមិនអាចប្រើជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធបានឡើយ។

១២ ក) ៣) ការប្រទាននិមិត្ត និង ការដឹកនាំ

ខ) ២) ការប្រទានព្រះអំណោយទាន

គ) ១) ជះឥទ្ធិពលទៅលើឫទ្ធានុភាពចម្បងសម្រាប់ជីវិត និង ការបម្រើ។

ឃ) ៥) ការប្រទានប្រាជ្ញា និង សេចក្ដីក្លាហាន

ង) ៤) ការដោះស្រាយបញ្ហា

## ការប្រឡងជំពូកទីមួយ

ពេលនេះ ដោយអ្នកបានបញ្ចប់ជំពូកទីមួយ ជាស្ថាពរ អ្នកអាចឆ្លើយសំណួរ*ការប្រឡងតាមជំពូក*បានហើយ។ សូមរំឭកមេរៀនកន្លងមកឡើងវិញ មុនពេលដែលអ្នកចាប់ផ្ដើម។ សូមធ្វើតាមការណែនាំដោយយកចិត្តទុកដាក់ ដើម្បីសម្រេចការប្រឡងនេះ ហើយសូមបន្តទៅជំពូកទីពីរទៀត។